ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**(គ.ជ.អ.ប)**

# សៀវភៅណែនាំស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ

# សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ខែមិថុនា ឆ្នាំ ២០១៩

# អារម្ភកថា

ស្របពេលដែលសកលលោកបាន និងកំពុងផ្លាស់ប្តូរពីវិធីសាស្ត្រនៃការអភិវឌ្ឍផ្អែកតាមគម្រោង ទៅជាវិធីសាស្ត្រនៃការអភិវឌ្ឍផ្អែកតាមកម្មវិធី រាជរដ្ឋាភិបាលកម្ពុជាក៏បានជ្រើសរើសវិធីសាស្ត្រ នៃការអភិវឌ្ឍដោយផ្អែកលើកម្មវិធី និងយុទ្ធសាស្ត្រជាតិ តាមរយៈការកំណត់អាទិភាព និងគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព។ វិធីសាស្ត្រនេះ មិនមែនគ្រាន់តែជាមធ្យោបាយក្នុងការប្រមូលផ្តុំគម្រោងតាមវិស័យឲ្យទៅជាកម្មវិធីមួយប៉ុណ្ណោះទេ ប៉ុន្តែវិធីសាស្ត្រនេះ បានប្រមូលផ្តុំនូវរបៀបរបបនៃការរៀបចំផែនការ ការអនុវត្ត ការតាមដាន វាយតម្លៃ និងការគ្រប់គ្រងនានា ព្រមទាំងការកៀរគរនិងការចូលរួមចំណែកជាបច្ចេកទេស និងធនធានពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា ដើម្បីឆ្លើយតបនឹងអាទិភាពនិងគោលដៅអភិវឌ្ឍជាតិ ក្នុងក្របខណ្ឌពេលវេលាជាក់លាក់។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំណត់ការជំរុញការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការដាក់ចេញនូវកម្មវិធីជាតិរយៈពេល១០ឆ្នាំ ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលត្រូវដឹកនាំសម្របសម្រួលការអនុវត្តដោយគ.ជ.អ.ប.។ អាស្រ័យហេតុនេះ គ.ជ.អ.ប. រំពឹងទុកថានឹងផ្តល់នូវលទ្ធផលជាក់លាក់ក្នុងការអនុវត្តកម្មវិធីជាតិ និងធានាគណនេយ្យភាពដល់រាជរដ្ឋាភិបាល និងដៃគូរបស់ខ្លួនអំពីរបៀប ដែលធនធានត្រូវបានប្រើប្រាស់ និងលទ្ធផលដែលត្រូវសម្រេចឲ្យបាន ដើម្បីធានាថាលទ្ធផលទាំងនោះ នាំមកនូវវឌ្ឍនភាពនៃការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាព ព្រមទាំងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។

ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវលទ្ធផល និងសមិទ្ធផលរំពឹងទុកទាំងនេះ ការងារត្រួតពិនិត្យនិងវាយតម្លៃត្រូវបានចាត់ទុកជាកិច្ចការដ៏សំខាន់មួយក្នុងការពិនិត្យ កែតម្រូវ និងតម្រង់ទិសការអនុវត្តផែនការសកម្មភាព កម្មវិធី និងក្របខណ្ឌគតិយុត្តនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ លើសពីនេះ ការត្រួតពិនិត្យ និងវាយតម្លៃ ក៏ជួយថ្នាក់ដឹកនាំគ.ជ.អ.ប. ក្នុងការទទួលបាននូវព័ត៌មាន និងភស្តុតាងជាមូលដ្ឋាន សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំផែនការយុទ្ធសាស្ត្រ និងការកៀរគរធនធាននានា។ ដូចនេះ ការត្រួតពិនិត្យ និងវាយតម្លៃគឺជាការវាស់វែងដ៏សំខាន់ ដើម្បីសម្រេចឲ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នក្នុងការគ្រប់គ្រងការអនុវត្ត និងពង្រឹងការអនុវត្តការងារ។ ជារួម ប្រសិនបើយើងគ្មានឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃ យើងប្រាកដជាមិនអាចវាស់វែងពីសមិទ្ធផលបានទេ ហើយយើងក៏មិនអាចគ្រប់គ្រងការអនុវត្តបានផងដែរ។

ផ្អែកតាមអត្ថប្រយោជន៍នៃការត្រួតពិនិត្យ និងវាយតម្លៃ សៀវភៅណែនាំស្តីពីការត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជួយគាំទ្រ គ.ជ.អ.ប. និងស្ថាប័នអនុវត្តជ.អ.៣ ជាពិសេសគឺមន្ត្រីទទួលបន្ទុកតាមដាន និងវាយតម្លៃអំពីវិធីសាស្ត្រនិងឧបករណ៍នៃការត្រួតពិនិត្យ និងវាយតម្លៃមួយចំនួនដូចជា ការវាយតម្លៃគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការវាយតម្លៃផលប៉ះពាល់នៃកម្មវិធី ការតាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ការវាយតម្លៃលើការអភិវឌ្ឍសមត្ថភាព ការវាយតម្លៃអភិបាលកិច្ច ព្រមទាំងក្របខណ្ឌលទ្ធផលនៃជ.អ.៣។

ទោះបីជាសៀវភៅនេះ ផ្តោតសំខាន់ទៅលើស្ថាប័នអនុវត្តកម្មវិធីជ.អ.៣ ប៉ុន្តែសៀវភៅនេះក៏អាចជាធនធានដ៏មានសារៈសំខាន់ និងមានប្រយោជន៍សម្រាប់អ្នកអនុវត្តការត្រួតពិនិត្យ និងវាយតម្លៃទាំងអស់ ដែលមានគោលបំណងរួមក្នុងការធានាស្តង់ដារគុណភាពវិជ្ជាជីវៈក្នុងការត្រួតពិនិត្យនិងវាយតម្លៃ និងការផ្តល់សេវាសាធារណៈប្រកប

ដោយប្រសិទ្ធភាពជូនប្រជាពលរដ្ឋ។ ដើម្បីឲ្យសៀវភៅនេះមានការចូលរួមចំណែកកាន់តែមានប្រសិទ្ធភាពថែមទៀត សំដៅសម្រេចគោលដៅ និងគោលបំណងនៃការអនុវត្តកម្មវិធីជាតិ គ.ជ.អ.ប. សូមស្វាគមន៍ និងទទួលយកនូវមតិយោបល់ និងធាតុចូលដ៏មានសារៈសំខាន់ពីអ្នកអានទាំងឡាយ។

ថ្ងៃ.........ខែ.........ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី....១៤....ខែ.........ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង**

**ជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

# បញ្ជីមាតិកា

**ទំព័រ**

បញ្ជីមាតិកា ..... i
តារាង ..... iii
បញ្ជីអក្សរកាត់ ..... iv
វាក្យស័ព្ទ ..... v

**ជំពូកទី១**

**សេចក្តីផ្តើម**

១.១.សេចក្តីផ្តើម ..... ១
១.២.រចនាសម្ព័ន្ធ នៃសៀវភៅណែនាំ ..... ២

**ជំពូកទី២**

**ការគាំទ្រដល់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប**

២.១.សេចក្តីផ្តើម ..... ៣
២.២.ដំណើរការរៀបចំ ផ.ស.ថ ..... ៦
២.៣.លទ្ធផលរំពឹងទុកជាអាទិភាព និងចំណុចដៅ ..... ៧
២.៤.ការរៀបចំសូចនាករ ..... ៧
២.៥.ការរៀបចំក្របខណ្ឌពេលវេលា នៃការអនុវត្តសកម្មភាព ..... ៩
២.៦.ការរៀបចំឯកសារ ផ.ស.ថ របស់ គ.ជ.អ.ប ..... ៩
២.៧.ការរៀបចំសេចក្តីសម្រេចរួម(កិច្ចសន្យា) ..... ៩
២.៨.សមត្ថភាព និងចំណេះដឹងចាំបាច់របស់មន្ត្រី គ.ជ.អ.ប ..... ៩

**ជំពូកទី៣**

**របាយការណ៍វឌ្ឍនភាព**

៣.១.សេចក្តីផ្តើម ..... ១០
៣.២.របាយការណ៍វឌ្ឍនភាព នៃការអនុវត្ត ផ.អ៣ ..... ១០
៣.៣.ស្ថានភាពថវិកា នៃកម្មវិធីអនុវត្ត ផ.អ.៣ ..... ១១
៣.៤.ក្របខណ្ឌលទ្ធផល នៃ ផ.អ.៣ ..... ១២

**ជំពូកទី៤**

**ការអង្កេតអភិបាលកិច្ច**

៤.១.សេចក្តីផ្តើម ..... ១៣
៤.២.សូចនាករអភិបាលកិច្ច ..... ១៣
៤.៣.ដំណើរការ នៃការអង្កេតអភិបាលកិច្ច ..... ១៤
៤.៤.សមត្ថភាព នៃការរៀបចំរបាយការណ៍ ..... ១៧
៤.៥.ការស្រាវជ្រាវ និងចែករំលែកទិន្នន័យនាពេលអនាគត ..... ១៧

## ជំពូកទី៥

## ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ


៥.១.សេចក្តីផ្តើម ........ ១៨
៥.២.ដំណើរការវាយតម្លៃការអភិវឌ្ឍសមត្ថភាព ........ ១៩
៥.៣.ការពិនិត្យសូចនាករឡើងវិញ ........ ១៩
៥.៤.ការកែសម្រួលទម្រង់កម្មវិធីអង្កេត ........ ១៩
៥.៥.ការបណ្តុះបណ្តាល ........ ១៩
៥.៦.ការប្រមូល និងបញ្ចូលទិន្នន័យ ........ ២០
៥.៧.ការទាញទិន្នន័យនៅក្នុងប្រព័ន្ធទិន្នន័យ ........ ២០
៥.៨.ការរៀបចំរបាយការណ៍ ........ ២១


## ជំពូកទី៦

## ការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ


៦.១.សេចក្តីផ្តើម ........ ២២
៦.២.ក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ ........ ២២
៦.៣.ផែនការសកម្មភាពត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ ........ ២៣


## ជំពូកទី៧

## ការវាយតម្លៃផលប៉ះពាល់


៧.១.សេចក្តីផ្តើម ........ ២៤
៧.២.ដំណើរការ នៃការវាយតម្លៃផលប៉ះពាល់ ........ ២៥
៧.៣.ទិន្នន័យ និងម៉ូឌែលនៃផលប៉ះពាល់ ........ ២៥
៧.៤.របៀបវារៈ នៃការស្រាវជ្រាវ ........ ២៧
៧.៥.សកម្មភាពលើកកម្ពស់ការវាយតម្លៃ ........ ២៧


## ជំពូកទី៨

## ក្របខណ្ឌលទ្ធផល


៨.១.សេចក្តីផ្តើម ........ ២៩
៨.២.សូចនាករផលប៉ះពាល់ ........ ២៥
៨.៣.សូចនាករសមិទ្ធផល ........ ២៩
៨.៤.សូចនាករអនុវត្តសកម្មភាព និងលទ្ធផលរំពឹងទុក ........ ២៩

## តារាង

តារាងទី១ ឧទាហរណ៍ នៃផែនការសកម្មភាព ..... ៤
តារាងទី២ ទិន្នន័យត្រួតពិនិត្យទូទៅ ..... ៤
តារាងទី៣ ឯកសារពាក់ព័ន្ធនឹង ផ.ស.ថ ..... ៥
តារាងទី៤ ដំណើរការទូទៅនៃការរៀបចំ ផ.ស.ថ ..... ៦
តារាងទី៥ ឧទាហរណ៍ នៃសូចនាករស្តង់ដារសម្រាប់សកម្មភាព និងលទ្ធផលរំពឹងទុក ..... ៨
តារាងទី៦ ផែនការការងារសម្រាប់ការអង្កេតអភិបាលកិច្ច ..... ១៤
តារាងទី៧ វិធីសាស្ត្រវាយតម្លៃផលប៉ះពាល់ ..... ២៥
តារាងទី៨ ទិន្នន័យដែលអាចរកបាន ..... ២៦
តារាងទី៩ ក្របខណ្ឌលទ្ធផល ..... ៣១

# បញ្ជីអក្សរកាត់

| | |
|---|---|
| គ.ជ.អ.ប | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| កម្មវិធីជាតិ | កម្មវិធីជាតិរយៈពេល១០ឆ្នាំនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| ផ.អ.៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំនៃកម្មវិធីជាតិ |
| ផ.ស.ថ | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| ផ.អ.៣ទី៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី៣នៃកម្មវិធីជាតិ |
| BoG | គណៈអភិបាល |
| CDB | ប្រព័ន្ធទិន្នន័យឃុំ សង្កាត់ |
| CSOs | អង្គការសង្គមស៊ីវិល |
| CSPF | កញ្ចប់ថវិកានៃភាពជាដៃគូជាមួយសង្គមស៊ីវិល |
| LCPF | កញ្ចប់ថវិកានៃភាពជាដៃគូជាមួយសហគមន៍មូលដ្ឋាន |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MoI | ក្រសួងមហាផ្ទៃ |
| MEID | អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន |
| MIS | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង |
| SIF | កញ្ចប់ថវិកានៃការផ្តួចផ្តើមគំនិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SNDD | ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| SNIF | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| SPD | ប្រព័ន្ធទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ |

# វាក្យសព្ទ

| ពាក្យ | និយមន័យ |
|---|---|
| គណនេយ្យភាព (accountability) | កាតព្វកិច្ចរបស់អ្នកទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាច ដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនោះ។ |
| សកម្មភាព (activity) | ការងារដែលត្រូវអនុវត្តដោយប្រើប្រាស់នូវធាតុចូលនានាដូចជាថវិកា ជំនួយបច្ចេកទេស និងធនធានផ្សេងទៀតដែលបានគៀរគរ ដើម្បីផលិតចេញជាលទ្ធផលជាក់លាក់នានា |
| អភិបាលកិច្ច (governance) | វិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាពប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ |
| ផលប៉ះពាល់ (impact) | ឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមាន ដោយផ្ទាល់ ឬដោយប្រយោលដែលកើតចេញពីអន្តរាគមន៍អភិវឌ្ឍន៍ ដោយផ្ទាល់ ឬដោយប្រយោល ដោយចេតនា ឬដោយអចេតនា |
| សូចនាករ (indicator) | កត្តា ឬអញ្ញតជាបរិមាណ ឬជាគុណភាពដែលផ្តល់នូវមធ្យោបាយនានា មានលក្ខណៈសាមញ្ញ និង អាចជឿទុកចិត្តបាន សម្រាប់ការវាស់វែងសមិទ្ធផលដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនានាកើតចេញពីអន្តរាគមន៍ណាមួយ ឬក៏ជួយក្នុងការវាយតម្លៃពីការបំពេញការងាររបស់ភ្នាក់ងារអភិវឌ្ឍន៍ណាមួយ |
| ធាតុចូល (input) | ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ធនធានសម្ភារៈ ដែលប្រើប្រាស់សម្រាប់អន្តរាគមន៍អភិវឌ្ឍន៍ |
| សមិទ្ធផល (outcome) | ឥទ្ធិពលរយៈពេលខ្លី និងរយៈពេលមធ្យមនៃលទ្ធផលនានារបស់អន្តរាគមន៍ |
| លទ្ធផលរំពឹងទុក (output) | ផលិតផល ឧបករណ៍ សម្ភារៈ និងសេវាទាំងឡាយដែលទទួលបានពីអន្តរាគមន៍អភិវឌ្ឍន៍ អាចរួមបញ្ចូលទាំងការផ្លាស់ប្តូរនានាដែលទទួលបានពីអន្តរាគមន៍ និងពាក់ព័ន្ធជាមួយនឹងការសម្រេចបាននៃសមិទ្ធផល |
| តម្លាភាព (Transparency) | ការផ្តល់នូវព័ត៌មានទាន់ពេលវេលា និងអាចជឿទុកចិត្តបាន ហើយព័ត៌មាននេះអាចទទួលបានការប្រើប្រាស់ដោយអ្នកពាក់ព័ន្ធទាំងអស់ |

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. សេចក្តីផ្តើម

សៀវភៅនេះ ពិពណ៌នាសង្ខេបអំពីការអនុវត្តការត្រួតពិនិត្យនិងវាយតម្លៃសំខាន់ៗរបស់គ.ជ.អ.ប។ សៀវភៅនេះមានគោលបំណងក្នុងការជួយដល់បុគ្គលិកផ្នែកត្រួតពិនិត្យ និងវាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងស្ថាប័នអនុវត្តជ.អ.៣ ក្នុងការអនុវត្តការតាមដាននិងវាយតម្លៃផ.ស.ថ ជ.អ.៣ និងកម្មវិធីជាតិ។ ឯកសារជ.អ.៣ ក៏បានលម្អិតបន្ថែមអំពីក្របខ័ណ្ឌលទ្ធផលជ.អ.៣ និងយុទ្ធសាស្រ្តត្រួតពិនិត្យនិងវាយតម្លៃ ដែលជាគន្លឹះក្នុងការតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាព នៃការអនុវត្តជ.អ.៣ផងដែរ។ បុគ្គលិកផ្នែកត្រួតពិនិត្យ និងវាយតម្លៃ ត្រូវសិក្សាយល់ដឹងអំពីសៀវភៅណែនាំស្តីពីការត្រួតពិនិត្យនិងវាយតម្លៃនេះ និងឯកសារក្របខណ្ឌលទ្ធផលជ.អ.៣ទាំងមូល (តារាងទី៩)។

សៀវភៅនេះត្រូវបានរៀបចំដោយផ្អែកលើឯកសារនិងសៀវភៅ៣ក់ព័ន្ធមួយចំនួនដូចខាងក្រោម៖

- យុទ្ធសាស្រ្តត្រួតពិនិត្យនិងវាយតម្លៃ និងក្របខ័ណ្ឌលទ្ធផលឆ្នាំ២០១៧ ជាឧបសម្ព័ន្ធនៃឯកសារ ជ.អ.៣ទី៣
- របាយការណ៍អង្កេតអភិបាលកិច្ចមូលដ្ឋានឆ្នាំ ២០១៣ និង២០១៦
- ផែនការសកម្មភាព និងថវិកាឆ្នាំ ២០១៧
- សៀវភៅណែនាំស្តីពីការរៀបចំសូចនាករនៃការអនុវត្តផែនការសកម្មភាព និងថវិកា
- សៀវភៅណែនាំស្តីពីការវាយតម្លៃសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- សៀវភៅណែនាំស្តីពីការរៀបចំទិន្នន័យនៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- របាយការណ៍វាយតម្លៃស្តីពីការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌឆ្នាំ២០១១
- របាយការណ៍ស្តីពីការវាយតម្លៃការអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៧
- របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧
- សៀវភៅណែនាំស្តីពីការបច្ចុប្បន្នភាពទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធCDB
- យុទ្ធសាស្រ្ត ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ
- និងឯកសារវាយតម្លៃផ្សេងៗទៀត

សៀវភៅនេះមិនសំដៅលើ:

- ➢ ការណែនាំអំពីទស្សនៈទូទៅនិងគោលការណ៍គ្រឹះនៃការត្រួតពិនិត្យនិងវាយតម្លៃនោះឡើយ។ ទស្សនៈទូទៅនិងគោលការណ៍គ្រឹះនៃការត្រួតពិនិត្យនិងវាយតម្លៃ ត្រូវបានចងក្រងនិងផ្សព្វផ្សាយជាច្រើននៅក្នុងប្រព័ន្ធអ៊ីនធឺណេត។ ដោយឡែក អង្គភាពត្រួតពិនិត្យ វាយតម្លៃនិងព័ត៌មានក៏ធ្លាប់បានផ្តល់វគ្គបណ្តុះបណ្តាលមួយចំនួនរួចមកហើយអំពីការត្រួតពិនិត្យ និងវាយតម្លៃដល់បុគ្គលិកផ្នែកតាមដាននិងវាយតម្លៃនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ➢ ការពិព័ណនាអំពីប្រព័ន្ធទិន្នន័យសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា ប្រព័ន្ធទិន្នន័យឃុំ សង្កាត់ ប្រព័ន្ធទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ និងប្រព័ន្ធផ្សេងទៀត

## ១.២. រចនាសម្ព័ន្ធ នៃសៀវភៅណែនាំ

សៀវភៅណែនាំនេះត្រូវបានបែងចែកជា៨ជំពូកដូចខាងក្រោមៈ

- ជំពូកទី១ ជាសេចក្តីផ្តើម
- ជំពូកទី២ បរិយាយអំពីការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
- ជំពូកទី៣ បរិយាយអំពីដំណើរការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ
- ជំពូកទី៤ បរិយាយអំពីការអង្កេតអភិបាលកិច្ច
- ជំពូកទី៥ បរិយាយអំពីការវាយតម្លៃសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ជំពូកទី៦ បរិយាយអំពីត្រួតពិនិត្យនិងវាយតម្លៃគោលនយោបាយ
- ជំពូកទី៧ បរិយាយអំពីការវាយតម្លៃផលប៉ះពាល់នៃគោលនយោបាយ ឬកម្មវិធី
- ជំពូកទី៨ សង្ខេបក្របខណ្ឌលទ្ធផល ផ.អ.៣ ដំណាក់កាលទី៣

# ជំពូកទី២

## ការគាំទ្រដល់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប

### ២.១. សេចក្តីផ្តើម

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានត្រូវដើរតួនាទីយ៉ាងសំខាន់ដើម្បីគាំទ្រដល់អង្គភាពគ្រប់គ្រង និង គាំទ្រកម្មវិធីក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ។ ផ្អែកតាមទស្សនៈនៃការត្រួតពិនិត្យនិងវាយតម្លៃ ជាការចាំបាច់ក្នុងការរៀបចំផែនការឲ្យបានត្រឹមត្រូវ បើមិនដូច្នេះទេ ការត្រួតពិនិត្យនិងវាយតម្លៃនឹងជួបការលំបាក។ ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំជាទូទៅ៖

- ត្រូវតែមានភាពច្បាស់លាស់ និងងាយយល់ បើមិនដូច្នេះទេយើងមិនអាចធ្វើការត្រួតពិនិត្យ និងធ្វើរបាយការណ៍បានទេ
- លទ្ធផលរំពឹងទុកនីមួយៗ ត្រូវមានចំនួនសកម្មភាពអប្បបរិមា និងស្របនឹងលទ្ធផលរំពឹងទុកនោះ។ ហើយផែនការសកម្មភាពត្រូវតែមានភាពសាមញ្ញនិងងាយយល់។ នៅពេលផែនការសកម្មភាព មិនស្របនឹងគោលដៅរំពឹងទុក នោះរបាយការណ៍ក៏មិនអាចឆ្លុះបញ្ចាំងការអនុវត្តទេ។ម្យ៉ាងវិញទៀត ការលើកផែនការសកម្មភាពធំពេកនឹងផ្តល់ផលវិបាកក្នុងការអនុវត្តផងដែរ។ ផែនការសកម្មភាពត្រូវកំណត់ឲ្យបានច្បាស់លាស់នូវចំណុចសំខាន់ៗ ដែលអាចឆ្លើយតបទៅនឹងអ្វីដែលជ.អ.៣គ្រោងអនុវត្ត និងសម្រេចឲ្យបាន។
- សកម្មភាពគ្រោងត្រូវតែមានលំដាប់លំដោយ ភ្ជាប់ជាមួយតារាងពេលវេលា នៃការអនុវត្តពិតប្រាកដ។

  សកម្មភាពមួយចំនួនត្រូវបានគ្រោងចាប់ផ្តើមអនុវត្តនៅ "ត្រីមាសទី១" និងសម្រេចបាននៅ"ត្រីមាសទី៤"

ដើម្បីកំណត់នូវព័ត៌មានឬទិន្នន័យអ្វីខ្លះដែលត្រូវការនៅក្នុងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ចាំបាច់ត្រូវកំណត់សិនថាតើអ្វីខ្លះដែលត្រូវការត្រួតពិនិត្យ។ ដូចដែលមានភ្ជាប់នៅក្នុងតារាងទី៣ ចំណុចដែលត្រូវការមានដូចខាងក្រោម៖

- **លទ្ធផល:** ជួរឈរទី១ជា"លទ្ធផល" ដែលបានរៀបចំតាមឋានានុក្រមដូចជាសមាសភាព សមិទ្ធផល លទ្ធផលរំពឹងទុក សកម្មភាព និងធាតុចូល
- **សូចនាករ:** លទ្ធផលរំពឹងទុកឬសកម្មភាពនីមួយៗ ត្រូវបានត្រួតពិនិត្យផ្អែកតាមចង្កោមនៃសូចនាករ។ លទ្ធផលរំពឹងទុកនិងសកម្មភាព អាចមិនមានសូចនាករ ឬអាចមានមួយឬច្រើន។ សូចនាករគឺជាតួលេខឬទិន្នន័យដែលត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃឬវាស់វែងលទ្ធផល ហើយដែលជាទូទៅជាទិន្នន័យបែបបរិមាណ។ ដោយសារផែនការសកម្មភាពមានទំហំធំ ដូចនេះមិនចាំបាច់ភ្ជាប់សូចនាករទៅនឹងលទ្ធផលនីមួយៗនោះទេ។ លទ្ធផលមិនមានសូចនាករពីព្រោះ (១)ចង្កោមសកម្មភាព(សកម្មភាព លទ្ធផលរំពឹងទុក) អាចនឹងមានអត្ថន័យមិនច្បាស់លាស់និងមិនអាចវាស់វែងបាន (២).លទ្ធផលមួយចំនួនមិនចាំបាច់ត្រូវចំណាយពេលក្នុងការប្រមូលទិន្នន័យ (៣).ចង្កោមសកម្មភាពមួយចំនួនអាចមានពាក្យស្ទួនគ្នា ឧទាហរណ៍ នៅក្នុងតារាងទី២ សកម្មភាព១.២.១.១.៣ មានអត្ថន័យដូចគ្នាទៅនឹងលទ្ធផលរំពឹងទុក ១.២.១.១ ហើយសូចនាករត្រូវបានកំណត់ សម្រាប់វាស់វែងលទ្ធផលរំពឹងទុករួចហើយ ដូចនេះត្រង់សកម្មភាពនេះ ពុំត្រូវបានកំណត់ឲ្យមានសូចនាករទៀតទេ។

## តារាងទី១ : ឧទាហរណ៍ នៃផែនការសកម្មភាព

| កូដ | លទ្ធផល | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **1.2.1.1** | បញ្ចប់ការពិនិត្យមើលឡើងវិញមុខងារដែលត្រូវផ្ទេរដោយក្រសួង ស្ថាប័ន | x | x | x | x | x | x | x | x | x | x | x | x |
| 1.2.1.1.1 | រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការពិនិត្យមើលឡើងវិញនូវមុខងារដែលត្រូវផ្ទេរ | x | x | x | | | | | | | | | |
| 1.2.1.1.2 | បញ្ចប់ការរៀបចំផែនទីមុខងាររបស់ក្រសួង ស្ថាប័ន | | | | x | x | x | x | x | x | | | |
| 1.2.1.1.3 | បញ្ចប់ការពិនិត្យមើលឡើងវិញមុខងារដែលត្រូវផ្ទេរដោយក្រសួង ស្ថាប័ន | | | | | | | | | | x | x | x |
| **1.2.1.2** | រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការពិនិត្យមើលឡើងវិញនូវការផ្ទេរមុខងារ | x | x | x | x | x | x | x | x | x | x | x | x |
| 1.2.1.2.1 | កំណត់ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការផ្ទេរមុខងារ | x | x | x | x | x | x | | | | | | |
| 1.2.1.2.1 | រៀបចំលិខិតបទដ្ឋានគតិយុត្ត | | | | | | | x | x | x | x | x | x |

## តារាងទី២: ទិន្នន័យត្រួតពិនិត្យទូទៅ

| លទ្ធផល | បរិយាយ | សូចនាករ | | | ថវិកា | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ដើមគ្រា | មករា-ធ្នូ | សម្រេចបាន | ថវិកា | ចំណាយ | សមតុល្យ | |
| **1.1. សមិទ្ធផល** | | | | | | | | |
| **1.1.1.លទ្ធផលរំពឹងទុកផ.អ.៣** | | | | | | | | |
| 1.1.2.1: **លទ្ធផលរំពឹងទុក ផ.ស.ថ** | សូចនាករ | | | | | | | |
| 1.1.2.1.1: **សកម្មភាព ផ.ស.ថ** | សូចនាករ | | | | | | | |
| មុខចំណាយ | សូចនាករ | | | | | | | |
| មុខចំណាយ | សូចនាករ | | | | | | | |
| 1.1.2.1.2: **សកម្មភាព ផ.ស.ថ** | សូចនាករ | | | | | | | |
| មុខចំណាយ | សូចនាករ | | | | | | | |
| មុខចំណាយ | សូចនាករ | | | | | | | |
| មុខចំណាយ | សូចនាករ | | | | | | | |

- **ចំណុចដៅសូចនាករ**: មិនមែនគ្រប់សូចនាករទាំងអស់ គួរមានឬអាចមានចំណុចដៅបាននោះទេ។ ទីមួយ សកម្មភាពឬលទ្ធផលរំពឹងទុកអាចជាផ្នែកមួយនៃដំណើរការ ហើយដែលលទ្ធផលនៃដំណើរការនោះមិនអាចកំណត់បាន។ឧទាហរណ៍ លទ្ធផលរំពឹងទុក១.១.២.១ នៅក្នុងតារាងទី៤។ ទីពីរ សូចនាករខ្លះ ពុំអាចកំណត់បាននូវចំណុចដៅជាមុនទេ។ ឧទាហរណ៍ វគ្គបណ្តុះបណ្តាលមួយ ត្រូវបានរៀបចំ ប៉ុន្តែចំណុចដៅនៃចំនួនស្ត្រីដែលនឹងចូលរួមវគ្គនេះ មានភាពពិបាកក្នុងការកំណត់ជាមុន។ សូចនាករបែបនេះ មិនមែនជាសូចនាករនៃការអនុវត្តមួយដ៏ល្អនោះទេ។
- **តម្លៃជាក់ស្តែងនៃសូចនាករ**: ជាតម្លៃជាក់ស្តែងប្រចាំឆ្នាំប៉ុន្តែតម្លៃជាក់ស្តែងប្រចាំឆ្នាំជាតម្លៃបូកយោងនិងប្រចាំត្រីមាស
- **ថវិកា**: ព័ត៌មានហិរញ្ញវត្ថុនិងថវិកាគ្រោង អាចទទួលបានពីអង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុ
- **ពេលវេលាអនុវត្តសកម្មភាព**: ពេលវេលាអនុវត្តសកម្មភាពប្រចាំខែគឺជាឧបករណ៍គ្រប់គ្រងយ៉ាងសំខាន់មួយ។ ដូចនេះ ចាំបាច់ត្រូវដឹងថាសកម្មភាពណាខ្លះ ដែលមិនបានចាប់ផ្តើមអនុវត្តតាមពេលវេលាគ្រោងឬបានបញ្ចប់ការអនុវត្តយឺតជាងផែនការដែលបានកំណត់។ ពេលវេលាចាប់ផ្តើមនិងបញ្ចប់ការអនុវត្តសកម្មភាពខ្លះមិនមាន

ភាពប្រាកដប្រជា ហើយសកម្មភាពជាច្រើនត្រូវបានអនុវត្តយឺតជាងផែនការរហូតដល់៦ខែ ១ឆ្នាំ ឬដល់២ឆ្នាំផងដែរ។

- **អនុសាសន៍**: ជាផ្នែកពិពណ៌នាអំពីវឌ្ឍនភាព ដែលបានផ្តល់ឲ្យដោយស្ថាប័នអនុវត្ត។ ហើយជាទូទៅ ផ្នែកនេះត្រូវបានសរសេរប្រហែលតែមួយកថាខណ្ឌប៉ុណ្ណោះ ដែលបង្ហាញពីសមិទ្ធផលសម្រេចបាន ឧបសគ្គ និងបញ្ហាប្រឈម។

ឯកសារគន្លឹះដែលអាចជួយពន្យល់អំពីផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ រួមទាំងដំណើរការនៃការរៀបចំ ផ.ស.ថនោះ មានដូចខាងក្រោម៖

**តារាងទី៣: ឯកសារពាក់ព័ន្ធនឹង ផ.ស.ថ**

| ឯកសារ | បរិយាយ |
|---|---|
| ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ | ឯកសារពិពណ៌នាអំពីទម្រង់នៃផ.ស.ថ ត្រូវបានរៀបចំឡើងដោយអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី |
| តារាងសូចនាករស្តង់ដា ក្នុងកម្មវិធី Excel សម្រាប់ការកំណត់សូចនាករនានាតាមសកម្មភាព និងលទ្ធផលរំពឹងទុក | តារាងនេះ ពិព័ណ៌នាអំពីការរៀបចំសូចនាករនានា តាមសកម្មភាព និងលទ្ធផលរំពឹងទុក នៅក្នុងផ.ស.ថ។ ហើយតារាងនេះត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ |
| ឧបករណ៍បង្កើតសូចនាករស្តង់ដាររបស់ផ.ស.ថ | ឧបករណ៍នេះជាប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលបានប្រើប្រាស់សម្រាប់រៀបចំសូចនាករស្តង់ដា ហើយត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រប់ព័ត៌មានវិទ្យា ដែលមានឈ្មោះថាប្រព័ន្ធទិន្នន័យថវិកាជាតិ។ ហើយក៏មានសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធនេះផងដែរ។ |
| ក្របខណ្ឌលទ្ធផលនៃ ផ.អ.៣ដំណាក់កាលទី៣ | ក្របខណ្ឌលទ្ធផល ដែលបានកែសម្រួលរួចរាល់ គឺជាតារាងសង្ខេបអំពីសូចនាករ ដែលត្រូវអនុវត្ត ហើយមាននៅក្នុងឧបសម្ព័ន្ធ១នៃ ផ.អ.៣ដំណាក់កាលទី៣ |
| សៀវភៅណែនាំស្តីពីប្រព័ន្ធទិន្នន័យផែនការថវិកាជាតិ | សៀវភៅណែនាំនេះពិព័ណ៌នាអំពីធាតុសំខាន់ៗនៃដំណើរការរៀបចំផែនការ រួមមាន ការកំណត់ និងរៀបចំសូចនាករសម្រាប់សកម្មភាព និងលទ្ធផលរំពឹងទុក និងរបៀបនៃការអនុវត្ត |
| សៀវភៅណែនាំស្តីពីការរៀបចំផែនការសកម្មភាព និងថវិកា | ឯកសារនេះពិពណ៌នាអំពីដំណើរការរៀបចំផ.ស.ថ ទម្រង់នៃសេចក្តីសម្រេចរួម (កិច្ចព្រមព្រៀង) រវាងគ.ជ.អ.ប និងស្ថាប័នអនុវត្ត ផ.អ.៣ ការអនុវត្តផ.ស.ថ ព្រមទាំងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផ.ស.ថ |
| សេចក្តីសម្រេចរួមលើការអនុវត្ត ផ.ស.ថ | អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធីជាអ្នកផ្តល់នូវគំរូសេចក្តីរួមនេះ។ |

## ២.២. ដំណើរការរៀបចំ ផ.ស.ថ

ដំណើរការរៀបចំផ.ស.ថ ត្រូវបានធ្វើឡើងផ្អែកតាមសៀវភៅណែនាំស្តីពីការរៀបចំផែនការសកម្មភាព និងថវិកា។ ជាពិសេស ដំណើររៀបចំផែនការនិងត្រួតពិនិត្យ នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យផែនការថវិកាជាតិ (NAD)។ ទោះជាយ៉ាងនេះក៏ដោយ ដំណើរការនៃការរៀបចំផ.ស.ថត្រូវបានសង្ខេបនៅក្នុងតារាងដូចខាងក្រោម៖

**តារាងទី៤: ដំណើរការឆ្នាំ នៃការរៀបចំ ផ.ស.ថ**

| ល.រ | ជំហាន | សកម្មភាព | ពេលវេលា |
|---|---|---|---|
| 1. | ពិនិត្យមើលឡើងវិញការអនុវត្តផ.ស.ថឆ្នាំកន្លងមក និង ផ.អ.៣ និងរៀបចំលទ្ធផលព្រាងបឋម | លេខាធិការដ្ឋានគ.ជ.អ.បនឹងពិនិត្យឡើងវិញលើការអនុវត្ត ផ.ស.ថឆ្នាំកន្លងមក និងផ.អ.៣ ព្រមទាំងរៀបចំសេចក្តីព្រាងបឋមស្តីពីសកម្មភាព និងលទ្ធផលរំពឹងទុកសម្រាប់ស្ថាប័នអនុវត្តផ.អ.៣ | ត្រីមាសទី១ |
| 2. | ប៉ានស្មាន និងកៀរគរ ធនធានសម្រាប់ផ.ស.ថ ពី រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ | លេខាធិការដ្ឋានរៀបចំកិច្ចប្រជុំជាមួយនឹងស្ថាប័ន អនុវត្ត ផ.អ.៣ ដើម្បីណែនាំអំពីការរៀបចំផ.ស.ថ និងគម្រោងផែនការថវិកា | ត្រីមាសទី២ |
| 3. | រៀបចំសេចក្តីព្រាងផ.ស.ថ | ស្ថាប័នអនុវត្តផ.អ.៣នីមួយៗរៀបចំសកម្មភាព និងលទ្ធផលរំពឹងទុកផ្អែកលើសកម្មភាពនិងលទ្ធផលរំពឹងទុកបឋម | ត្រីមាសទី២ |
| 4. | ពិនិត្យមើលឡើងវិញផ.ស.ថ | លេខាធិការដ្ឋានគ.ជ.អ.ប ពិនិត្យឡើងវិញនិងវាយតម្លៃសេចក្តីព្រាងផ.ស.ថ ដែលរៀបចំដោយស្ថាប័នអនុវត្តផ.អ.៣នីមួយ | ត្រីមាសទី២ |
| 5. | សេចក្តីព្រាងផ.ស.ថ រួមមានអាទិភាព និងចំណុចដៅ | លេខាធិការដ្ឋានគ.ជ.អ.ប ធ្វើសមាហរណកម្មនិងរៀបចំសេចក្តីព្រាងផ.ស.ថនៃគ.ជ.អ.ប ផ្អែកលើសកម្មភាពនិងលទ្ធផលរំពឹងទុករបស់ស្ថាប័នអនុវត្តផ.អ.៣ | ត្រីមាសទី២ |
| 6. | រៀបចំសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប | លេខាធិការដ្ឋានគ.ជ.អ.ប នឹងរៀបចំសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប ដើម្បីធ្វើបទបង្ហាញ និងទទួលយកនូវអនុសាសន៍ពីស្ថាប័នអនុវត្តផ.អ.៣លើសេចក្តីព្រាងផ.ស.ថរបស់គ.ជ.អ.ប | ត្រីមាសទី២ |
| 7. | គ.ជ.អ.ប ពិនិត្យ និងសម្រេចលើឯកសារផ.ស.ថ | ផ្អែកលើលទ្ធផលនៃសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ លេខាធិការដ្ឋានគ.ជ.អ.ប ពិនិត្យមើលឡើងវិញ និងបញ្ចប់លើឯកសារផ.ស.ថ ហើយដាក់ជូនគ.ជ.អ.ប ពិនិត្យ និងសម្រេច | ត្រីមាសទី៣ |
| 8. | ពិនិត្យនិងសម្រេចលើសេចក្តីសម្រេចរួមរវាងគ.ជ.អ.ប និងក្រសួង ស្ថាប័ន រាជធានី ខេត្ត | ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តរៀបចំ និង ចុះហត្ថលេខាលើសេចក្តីសម្រេចរួមជាមួយគ.ជ.អ.ប លើការអនុវត្តផ.ស.ថរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត | ត្រីមាសទី៤ |

| ល.រ | ជំហាន | សកម្មភាព | ពេលវេលា |
|---|---|---|---|
| 9. | ពិនិត្យ និងសម្រេចលើសេចក្តីសម្រេចរួមរវាងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌលើការអនុវត្តផ.ស.ថ | ខេត្ត ក្នុងនាមគ.ជ.អ.ប ចុះហត្ថលេខាលើសេចក្តីសម្រេចរួមរវាងរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកលើការអនុវត្តផ.ស.ថរបស់ក្រុងស្រុក | ត្រីមាសទី៤ |

## ២.៣. លទ្ធផលរំពឹងទុកជាអាទិភាព និងចំណុចដៅ

លទ្ធផលរំពឹងទុកមាន២ប្រភេទនៅក្នុងផ.ស.ថ គឺ ១).លទ្ធផលរំពឹងទុកជាអាទិភាព និងលទ្ធផលរំពឹងទុកសម្រាប់គាំទ្រនិងប្រតិបត្តិ។ លទ្ធផលរំពឹងទុកជាអាទិភាព គឺជាលទ្ធផលសំខាន់ៗដែលត្រូវតែអនុវត្តនៅក្នុងឆ្នាំនីមួយៗ។ លទ្ធផលរំពឹងទុកទាំងនោះត្រូវបានកំណត់ផ្អែកលើលទ្ធផលរំពឹងទុក និងសកម្មភាពសំខាន់ៗនៅក្នុងផ.អ.៣ និងផ្អែកលើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធដទៃទៀត។ លទ្ធផលរំពឹងទុកជាអាទិភាពនីមួយៗមានសកម្មភាពសំខាន់ៗមួយចំនួនដែលហៅថាចំណុចដៅជាអាទិភាព (Milestones)។

ចំណុចដៅជាអាទិភាពគឺជាសកម្មភាពសំខាន់ៗ នៃលទ្ធផលរំពឹងទុកជាអាទិភាព ដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់ព្រឹត្តិការណ៍អាទិភាពនៅក្នុងក្របខណ្ឌពេលវេលាមួយ ដូចជាការសម្រេចបាននូវព្រឹត្តិការណ៍ ឬជំហានសំខាន់មួយ។ ចំណុចដៅជាអាទិភាពទាំងនោះត្រូវបានជ្រើសរើស ដោយសារចំណុចដៅទាំងនោះតំណាងឲ្យវឌ្ឍនភាពជារួម និងត្រូវបានប្រើប្រាស់សម្រាប់តាមដានវឌ្ឍនភាពឆ្ពោះទៅការផ្លាស់ប្តូរជាយុទ្ធសាស្ត្រ។ អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី និងអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានគួរយល់ស្របគ្នាក្នុងការរៀបចំចង្កោមនៃចំណុចដៅជាអាទិភាពសំខាន់ៗ។ ដូចនេះ

- ប្រសិនបើចំណុចដៅទាំងនោះបានអនុវត្តសម្រេច បង្ហាញថាកម្មវិធីសម្រេចបានគោលដៅកំណត់។ ដូចនេះ ចំណុចដៅទាំងនោះ គួរកំណត់ថាជាអនុចង្កោមនៃលទ្ធផលរំពឹងទុកជាអាទិភាព ដែលគ្រោងសម្រេចឲ្យបាន
- ចំណុចដៅអាទិភាព ត្រូវបានផ្សព្វផ្សាយពេញមួយឆ្នាំ

## ២.៤. ការរៀបចំសូចនាករ

ប្រព័ន្ធទិន្នន័យមួយ ត្រូវបានបង្កើតឡើងដើម្បីរៀបចំសូចនាករស្តង់ដារសម្រាប់សកម្មភាព និងលទ្ធផលរំពឹងទុកនៃផ.ស.ថ។ ប្រព័ន្ធទិន្នន័យនេះត្រូវបានរៀបចំឡើងក្នុងកម្មវិធី Excel ហើយត្រូវបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ។ សូចនាករស្តង់ដារ ជាសូចនាករដែលអាចប្រមូលផ្តុំគ្នាពីសកម្មភាព និងលទ្ធផលរំពឹងទុកផ្សេងៗគ្នានៅក្នុងផ.ស.ថ។

**តារាងទី៥: ឧទាហរណ៍ នៃសូចនាករស្តង់ដារសម្រាប់សកម្មភាព និងលទ្ធផលរំពឹងទុក**

| ល.រ | សមិទ្ធផល | ចំណុចដៅ | LAs | IAs |
|---|---|---|---|---|
| | **លទ្ធផលរំពឹងទុក** | | | |
| **51** | **បញ្ចប់ការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** | | | |
| 5101 | ចំនួនអង្គភាពដែលបញ្ចប់ការវិភាគ/ពិនិត្យមើលឡើងវិញ | | | |
| 5102 | ចំនួនស្ថាប័នត្រូវបានរៀបចំឡើងវិញស្របតាមគោលនយោបាយវិមជ្ឈការ | | | |
| 5103 | ការចំណាយដែលបានព្យាករណ៍នៃការរៀបចំរចនាសម្ព័ន្ធឡើងវិញ (គិតជាលានដុល្លារសហរដ្ឋអាមេរិក) | | | |
| | **សកម្មភាព** | | | |
| **12** | វគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ វេទិកា និងព្រឹត្តិការណ៍នានា | | | |
| 1201 | ចំនួនវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ វេទិកា និងព្រឹត្តិការណ៍នានាដែលបានរៀបចំ | | | |
| 1202 | ចំនួនថ្ងៃ នៃវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ វេទិកា និងព្រឹត្តិការណ៍នានាដែលបានរៀបចំ | | | |
| 1203 | ចំនួនអ្នកចូលរួមសរុប | | | |
| 1204 | ចំនួនអ្នកចូលរួមជាស្ត្រី | | | |
| 1205 | ចំនួនអ្នកចូលរួមថ្នាក់ជាតិ | | | |
| 1206 | ចំនួនអ្នកចូលរួមថ្នាក់ក្រោមជាតិ | | | |
| 1207 | ចំនួនអ្នកចូលរួមជាស្ត្រីនៅថ្នាក់ជាតិ | | | |
| 1208 | ចំនួនអ្នកចូលរួមជាស្ត្រីនៅថ្នាក់ក្រោមជាតិ | | | |
| 1209 | ចំនួនរបាយការណ៍ដែលបានរៀបចំ | | | |
| 1210 | ចំនួនកំណត់ហេតុ រួមទាំងកិច្ចព្រមព្រៀងនិងអនុសាសន៍ដែលបានរៀបចំ | | | |

ជួរដេកនីមួយៗនៅក្នុងផ.ស.ថ (ឧទាហរណ៍ៈសកម្មភាព) អាចពិពណ៌នាអំពីព្រឹត្តិការណ៍ជាក់លាក់ណាមួយដែលបានអនុវត្ត។ ក្នុងករណីនេះ សូចនាករស្តង់ដារ (ឧ. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ) អាចជួយក្នុងការប្រមូលទិន្នន័យដូចគ្នាពីផែនការទាំងមូល ដែលដូចគ្នាផងដែរនឹងសូចនាករតាមដានអំពីចំនួនអ្នកដែលទទួលបានវគ្គបណ្តុះបណ្តាលឬក៏ចំនួនសិក្ខាសាលា ដែលបានរៀបចំ(ក៏មិនគិតពីប្រធានបទដូចគ្នា)។ ដូច្នេះលទ្ធផលជាក់លាក់ពិពណ៌នានូវអ្វីដែលសម្រេចបាន ហើយសូចនាករស្តង់ដាប្រមូលផ្តុំនូវលទ្ធផលទាំងនោះ។ ចុងក្រោយគោលបំណងនៃការរៀបចំសូចនាករស្តង់ដា គឺដើម្បីភ្ជាប់លទ្ធផលជាក់លាក់មួយនៅក្នុងផ.ស.ថទៅនឹងចង្កោមសូចនាករស្តង់ដារ។ វិធីងាយស្រួលមួយដើម្បីធ្វើកិច្ចការនេះ គឺបង្កើត"សកម្មភាពស្តង់ដារ"រយៈពេលមធ្យម ដូចជាការរៀបចំវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសនាមសម្រាប់រាជធានី ខេត្ត។ សៀវភៅណែនាំ NAD មានពិពណ៌នាអំពីការរៀបចំ សូចនាករស្តង់ដារសម្រាប់លទ្ធផលរំពឹងទុក និងសកម្មភាព។

## ២.៥. ការរៀបចំក្របខណ្ឌពេលវេលា នៃការអនុវត្តសកម្មភាព

វាមានសារៈសំខាន់ដែលត្រូវមានកំណត់ត្រាអំពីពេលវេលាគ្រោងចាប់ផ្ដើម និងគ្រោងបញ្ចប់ការអនុវត្តសកម្មភាពនានា។ ហើយការកត់ត្រានេះ ត្រូវធ្វើឡើងជារៀងរាល់ខែ ឧទាហរណ៍ៈការរៀបចំផែនទីផ្ទេរមុខងារ នឹងចាប់ផ្ដើមសិក្សាពីខែមករាដល់ខែមីនា។ ហើយអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធីនឹងពិនិត្យមើលក្របខណ្ឌពេលវេលានៃសកម្មភាព ដើម្បីធានាថាសមស្រប និងត្រឹមត្រូវ។

## ២.៦. ការរៀបចំឯកសារ ផ.ស.ថ របស់ គ.ជ.អ.ប

ជារៀងរាល់ឆ្នាំ ឯកសារផ.ស.ថរបស់គ.ជ.អ.ប នឹងត្រូវបានរៀបចំ។ ឯកសារផ.ស.ថនេះ ត្រូវមាតិកាដូចខាងក្រោមៈ

- ទិដ្ឋភាពទូទៅ
- សេចក្តីសង្ខេប នៃលទ្ធផលរំពឹងទុកជាអាទិភាពដែលត្រូវបានបញ្ចប់តាមឆ្នាំនីមួយៗ
- សេចក្តីសង្ខេបហិរញ្ញវត្ថុ
- ការពិពណ៌នាអំពីលទ្ធផលរំពឹងទុក និងចំណុចដៅសំខាន់ៗដែលត្រូវបានកំណត់នៅតាមសមាសភាគនៃជ.អ.៣
- សកម្មភាពលម្អិត ហិរញ្ញវត្ថុ ស្ថាប័នឬអង្គភាពអនុវត្ត និងក្របខណ្ឌពេលវេលា

## ២.៧. ការរៀបចំសេចក្តីសម្រេចរួម(កិច្ចសន្យា)

នៅពេលដែលផ.ស.ថរបស់គ.ជ.អ.បត្រូវបានអនុម័ត សេចក្តីសម្រេចរួមរវាងគ.ជ.អ.ប និងស្ថាប័នអនុវត្តជ.អ.៣(ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ជាដើម) លើការអនុវត្តផ.ស.ថរបស់គ.ជ.អ.ប នឹងរៀបចំនិងចុះហត្ថលេខា។ គណៈអភិបាលរដ្ឋបាលរាជធានី ខេត្ត ក្នុងនាមគ.ជ.អ.ប នឹងចុះហត្ថលេខាលើសេចក្តីសម្រេចរួមសម្រាប់រដ្ឋបាលក្រុង ស្រុក។ ហើយសមាសធាតុសំខាន់នៃសេចក្តីសម្រេច រួមមានដូចខាងក្រោមៈ

- បទបញ្ញត្តិនៃសេចក្តីសម្រេចរួម ពិពណ៌នាអំពីគោលបំណងនៃសេចក្តីសម្រេច ការទទួលខុសត្រូវរបស់គ.ជ.អ.ប និងស្ថាប័នអនុវត្តជាដើម ។ល។
- តារាងសកម្មភាពលម្អិតនៃស្ថាប័នអនុវត្តជ.អ.៣នីមួយៗ រួមមាន ថវិកាគ្រោងសរុប លំហូរថវិកាស្ថាប័នឬអង្គភាពអនុវត្តសកម្មភាពនីមួយៗ
- តារាងក្របខណ្ឌពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ

## ២.៨. សមត្ថភាព និងចំណេះដឹងចាំបាច់របស់មន្ត្រី គ.ជ.អ.ប

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន និងអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីត្រូវមានៈ

- មានចំណេះដឹងយ៉ាងពេញលេញលើកម្មវិធីជាតិ និងជ.អ.៣
- មានចំណេះដឹងអំពីការរៀបចំផែនការ
- មានចំណេះដឹងពីការកំណត់ និងរៀបចំសូចនាករសម្រាប់សកម្មភាព និងលទ្ធផលរំពឹងទុក
- មានលទ្ធភាពរៀបចំ "សូចនាករស្តង់ដារនៅក្នុងផ.ស.ថ" និងមានចំណេះដឹងទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដើម្បីបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធគ្រប់គ្រងផែនការថវិកាជាតិ
- មានលទ្ធភាពរៀបចំរបាយការណ៍ជាភាសាខ្មែរ និងអង់គ្លេស

## ជំពូកទី៣
## របាយការណ៍វឌ្ឍនភាព

### ៣.១. សេចក្តីផ្តើម

របាយការណ៍ ផ.ស.ថ របស់គ.ជ.អ.ប ត្រូវបានរៀបចំឡើងរៀងរាល់ត្រីមាស (ចាប់ពីខែមករាដល់ខែមីនា) ហើយរបាយការណ៍ប្រចាំឆមាស (ចាប់ពីខែមករាដល់ខែមិថុនា) និងប្រចាំឆ្នាំ(ពីខែមករា ដល់ខែធ្នូ)។ ជាពិសេស របាយការណ៍នេះ ពិពណ៌នាអំពីវឌ្ឍនភាពនៃការអនុវត្តការងារដែលមាននៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងផែនការថវិកាជាតិ និងរបាយការណ៍ហិរញ្ញវត្ថុ ដែលសម្រេចបានដោយស្ថាប័នអនុវត្តផ.អ.៣ និងអ្នកពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ របាយកាណ៍នៃការអនុវត្តគម្រោងដាច់ដោយឡែក អាចត្រូវបានរៀបចំដោយផ្អែកលើកិច្ចព្រមព្រៀងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងដៃគូអភិវឌ្ឍន៍នីមួយៗ។ របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផ.ស.ថនេះ ត្រូវបានរៀបចំជាភាសាខ្មែរ ហើយបន្ទាប់មកបានបកប្រែជាភាសាអង់គ្លេសតាមការចាំបាច់។ ការរៀបចំរបាយការណ៍នេះ ត្រូវធ្វើឡើងជាទៀងទាត់ដោយស្ថាប័នអនុវត្តផ.អ.៣ តាមរយៈប្រព័ន្ធNAD ។

ប្រភពព័ត៌មានសំខាន់ៗដែលបានប្រើប្រាស់ ដើម្បីរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តផ.ស.ថ រួមមាន៖

- វឌ្ឍនភាពនៃការអនុវត្តផ.ស.ថរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ រួមទាំងសូចនាករ ដែលបានធ្វើបច្ចុប្បន្នភាព និងរាយការណ៍នៅក្នុងប្រព័ន្ធNAD ដោយស្ថាប័នអនុវត្តផ.អ.៣
- ស្ថានភាពហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដែលបានធ្វើបច្ចុប្បន្នភាព និងរាយការណ៍នៅក្នុងប្រព័ន្ធ NAD ដោយស្ថាប័នអនុវត្តផ.អ.៣
- វឌ្ឍនភាពទាក់ទងនឹងការងារលទ្ធកម្ម និងបុគ្គលិក ដែលត្រូវបានធ្វើបច្ចុប្បន្នភាព និរាយការណ៍នៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងបុគ្គលិក និងប្រព័ន្ធសារពើភ័ណ្ឌ ដោយស្ថាប័នអនុវត្តផ.អ.៣
- វឌ្ឍនភាពទូទៅនៃក្របខណ្ឌលទ្ធផល ដែលបានធ្វើបច្ចុប្បន្នភាពដោយលេខាធិការដ្ឋាន គ.ជ.អ.ប
- របាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់

ជាទូទៅ រចនាសម្ព័ន្ធនៃរបាយការណ៍វឌ្ឍនភាព មានដូចខាងក្រោម៖

- ទិដ្ឋភាពទូទៅ ពិពណ៌នាអំពីគោលបំណងនៃរបាយការណ៍ និងសង្ខេបសមិទ្ធផលសំខាន់ៗជាអាទិភាព រួមមាន ចំណុចដៅជាអាទិភាព សូចនាករ បញ្ហាប្រឈមសំខាន់ៗ និងតារាងចំណាយធៀបនឹងថវិកាគ្រោង
- វឌ្ឍនភាពលម្អិតនៃលទ្ធផលរំពឹងទុករបស់ផ.ស.ថទាំងអស់ដែលសម្រេចបាន និងបញ្ហាប្រឈម រួមទាំងសូចនាករ ទៅតាមសមាសភាគផ.អ.៣
- ឧបសម្ព័ន្ធដូចជា ស្ថានភាពហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម បុគ្គលិក និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

### ៣.២. របាយការណ៍វឌ្ឍនភាព នៃការអនុវត្តផ.អ.៣

ស្ថាប័នអនុវត្តផ.អ.៣ នឹងធ្វើបច្ចុប្បន្នភាព និងរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តសេចក្តីសម្រេចរួមនៅក្នុងប្រព័ន្ធNADជារៀងរាល់ខែ ដោយអនុលោមទៅតាមសៀវភៅណែនាំស្តីពីប្រព័ន្ធទិន្នន័យគ្រប់គ្រងផែនការ

ថវិកាជាតិ និងសៀវភៅណែនាំស្តីពីការរៀបចំផ.ស.ថ។ វឌ្ឍនភាពនៃការអនុវត្តផែនការ នឹងត្រូវបានធ្វើបច្ចុប្បន្នភាព ដោយផ្តោតលើ៖

- ក្របខណ្ឌពេលវេលានៃសកម្មភាព
- សូចនាករនៃសកម្មភាព និង
- របាយការណ៍សង្ខេបលើលទ្ធផលដែលសម្រេចសំខាន់ៗនិង បញ្ហាប្រឈម

លើសពីនេះ នៅចុងឆ្នាំ ស្ថាប័នអនុវត្តផ.អ.៣ នឹងរៀបចំរបាយការណ៍បញ្ចប់ការអនុវត្តកិច្ចព្រមព្រៀង ដើម្បីបិទបញ្ចប់ការអនុវត្តសេចក្តីសម្រេចរួម។

ជាទូទៅ របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចរួម មានព័ត៌មានសំខាន់ៗដូចខាងក្រោម៖

- សេចក្តីសង្ខេបប្រចាំឆ្នាំនៃលទ្ធផលសម្រេចបានសំខាន់ៗ រួមមាន ការចំណាយថវិកា បញ្ហាប្រឈម
- វឌ្ឍនភាពនៃការអនុវត្តលម្អិតតាមសកម្មភាព
- ការចំណាយតាមសកម្មភាព
- កិច្ចលទ្ធកម្ម
- របាយការណ៍វឌ្ឍនភាពនិងឯកសារពាក់ព័ន្ធផ្សេងទៀត។

## ៣.៣. ស្ថានភាពថវិកា នៃកម្មវិធីអនុវត្តផ.អ.៣

ផ្អែកលើសេចក្តីសម្រេចរួមដែលបានអនុម័តដោយគ.ជ.អ.បនិងតារាងផ.ស.ថនៅក្នុងប្រព័ន្ធNAD ស្ថាប័នអនុវត្តផ.អ.៣ ត្រូវរៀបចំបង្កើតអោយមានប្រព័ន្ធគណនេយ្យ Peachtree ដើម្បីកត់ត្រា និងតាមដានការប្រើប្រាស់ថវិកាសម្រាប់ការអនុវត្តសេចក្តីសម្រេចរួម។ ក្នុងករណីនេះ ស្ថាប័នអនុវត្តផ.អ.៣ នឹងរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែនៅក្នុងប្រព័ន្ធ Peachtree បន្ទាប់មកនាំចូលរបាយការណ៍នេះទៅក្នុងប្រព័ន្ធNAD ។

ផ្អែកតាមទិន្នន័យហិរញ្ញវត្ថុនៅក្នុងប្រព័ន្ធ ស្ថាប័នអនុវត្តផ.អ.៣ នឹងរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងផ្ញើមកលេខាធិការដ្ឋានគ.ជ.អ.ប ដើម្បីពិនិត្យផ្ទៀងផ្ទាត់។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មានព័ត៌មានសំខាន់ៗដូចខាងក្រោម៖

- សក្ខីប័ត្រកែតម្រូវ (Journal Voucher)
- តារាងសង្ខេបអំពីចំណាយសរុប ថវិកាគ្រោងសរុប និងសមតុល្យ
- ការពិនិត្យ និងផ្ទៀងផ្ទាត់គណនេយ្យ (Account reconciliation)
- សក្ខីប័ត្រទទួលប្រាក់ (Cash receipt journal)
- សក្ខីប័ត្រទូទាត់ (Cash disbursement journal)
- ទិន្នានុប្បវត្តសៀវភៅធំ (General ledger)
- របាយការណ៍បុរេប្រទាន (Advance statement)
- សេចក្តីសង្ខេបស្តីពីលំហូរសាច់ប្រាក់ (Cash flow profile summary)
- ចំណាយលម្អិតតាមសកម្មភាព

ទន្ទឹមនឹងនេះ នៅចុងឆ្នាំ ស្ថាប័នអនុវត្តផ.អ.៣ នឹងរៀបចំរបាយការណ៍បិទបញ្ជីគណនេយ្យនៃការអនុវត្តសេចក្តីសម្រេចរួម។ សមតុល្យថវិកាទាំងអស់នឹងត្រូវបញ្ជូនត្រឡប់មកលេខាធិការដ្ឋានគ.ជ.អ.ប សម្រាប់ប្រើប្រាស់នៅឆ្នាំបន្ទាប់។

របាយការណ៍បិទបញ្ជីគណនេយ្យនៃការអនុវត្តសេចក្តីសម្រេចរួម មានព័ត៌មានដូចខាងក្រោម៖

- សក្ខីប័ត្រកែតម្រូវ

- តារាងសង្ខេបអំពីចំណាយសរុប ថវិកាគ្រោងសរុប និងសមតុល្យ
- ការពិនិត្យ និងផ្ទៀងផ្ទាត់គណនេយ្យ
- សក្ខីប័ត្រទទួលប្រាក់
- សក្ខីប័ត្រទូទាត់
- ទិន្នានុប្បវត្តសៀវភៅធំ
- របាយការណ៍បុរេប្រទាន
- សេចក្តីសង្ខេបស្តីពីលំហូរសាច់ប្រាក់
- ចំណាយលម្អិតតាមសកម្មភាព

### ៣.៤. ក្របខណ្ឌលទ្ធផលនៃ ផ.អ.៣

យោងតាមក្របខណ្ឌលទ្ធផលជារួមនៃកម្មវិធី ផ.ស.ថ របស់ គ.ជ.អ.ប ត្រូវមានការកំណត់នូវសូចនាករនៃលទ្ធផលរំពឹងទុក និងចំណុចដៅ ដែលត្រូវសម្រេចឲ្យបានជារៀងរាល់ឆ្នាំ។ លេខាធិការដ្ឋានគ.ជ.អ.ប ត្រូវធ្វើបច្ចុប្បន្នភាពលើការសម្រេចបាននូវចំណុចដៅនានា (កម្រិតលទ្ធផលរំពឹងទុក) និងដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ។

# ជំពូកទី៤
## ការអង្កេតអភិបាលកិច្ច

### ៤.១. សេចក្តីផ្តើម

ការអង្កេតអភិបាលកិច្ច ត្រូវបានអនុវត្តដើម្បីតាមដាននិន្នាការអភិបាលកិច្ចក្នុងរយៈពេលកន្លងមក។ ក្នុងដំណើរការនៃការអង្កេតអភិបាលកិច្ច សូចនាករត្រូវបានរៀបចំយ៉ាងរៀបរយ ផ្អែកលើសំណួរស្ទង់មតិប្រមាណ២៥០។ បញ្ជីសំណួរស្ទង់មតិនេះចែកចេញជាពីរប្រភេទគឺ បញ្ជីសំណួរសម្រាប់ប្រជាពលរដ្ឋ និងបញ្ជីសំណួរសម្រាប់ក្រុមប្រឹក្សា ហើយបញ្ជីសំណួរសម្រាប់ប្រជាពលរដ្ឋត្រូវបានផ្តោតសំខាន់នៅក្នុងការអង្កេតនេះ។ ការអង្កេតនេះជាការស្ទាបស្ទង់មតិមួយដែលមានការកំណត់យ៉ាងជាក់លាក់អំពីវិធីសាស្ត្រដែលព័ត៌មានត្រូវយកមកបកស្រាយ។ ឧទាហរណ៍៖សំណួរអាចមានការយល់ច្រឡំឬមានការបកស្រាយខុស ហើយការឆ្លើយតបអាចមិនពិតប្រាកដ។ លទ្ធផលគឺពឹងផ្អែកយ៉ាងខ្លាំងលើពាក្យពេចន៍ នៃសំណួរការរៀបរៀងសំណួរ និងការសួរសំណួរជាដើម។ របាយការណ៍អង្កេតអភិបាលកិច្ចនៅឆ្នាំ២០១៣ និងឆ្នាំ២០១៦ បានបង្ហាញពីដែនកំណត់ដែលប៉ះពាល់ដល់ការស្ទង់មតិទាំងមូល ដោយសារតែហេតុនេះហើយបានជាចាំបាច់ត្រូវសិក្សានិងប្រៀបធៀបលទ្ធផលជាមួយប្រភពទិន្នន័យឬការសិក្សាអង្កេតផ្សេងទៀតដែលពាក់ព័ន្ធ។ ទោះបីមានដែនកំណត់យ៉ាងនេះក្តី ក៏ការអង្កេតនេះ បង្កើតឲ្យមានភាពត្រឹមត្រូវសមហេតុផល ហើយជាយន្តការមួយពិភាក្សា និងពិគ្រោះយោបល់អំពីអភិបាលកិច្ចមូលដ្ឋាន។ ការស្ទង់មតិនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដូចខាងក្រោម៖

- ការអង្កេតនេះត្រូវឡើងវិញរៀងរាល់៣ឆ្នាំម្តង
- ការអង្កេតនេះត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ហើយសំណួរនៃការអង្កេតនេះត្រូវបានរៀបចំឲ្យមានភាពខុសគ្នារវាងរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់
- ការស្ទង់មតិនេះបែងចែកលទ្ធផលជាក្រុមខុសៗគ្នា(បុរស/ស្ត្រី ក្រីក្រ/មិនក្រីក្រ ជនបទ/ទីប្រជុំជន)
- ការអង្កេតនេះមិនអាចសន្និដ្ឋានអំពីរដ្ឋបាលថ្នាក់ក្រោមជាតិឬតំបន់ណាមួយបានឡើយ ហើយមិនអាចប្រើប្រាស់ដើម្បីធ្វើការប្រៀបធៀបគ្នារវាងសន្ទស្សន៍ផ្សេងគ្នានៃអភិបាលកិច្ចបានឡើយ ឧទាហរណ៍៖ ការប្រៀបធៀបសន្ទស្សន៍តម្លាភាព និងគណនេយ្យភាព។
- ដោយសារលទ្ធផលនេះផ្តោតតិចតួចនៅថ្នាក់ឃុំ សង្កាត់ ដូចនេះលទ្ធផលនេះមានការពិបាកក្នុងការផ្សាភ្ជាប់ជាមួយនឹងទិន្នន័យនៃប្រព័ន្ធទិន្នន័យឃុំ សង្កាត់ ឬទិន្នន័យកម្រិតឃុំផ្សេងទៀត ដើម្បីធ្វើការវិភាគបែបស្ថិតិបានឡើយ។

### ៤.២. សូចនាករអភិបាលកិច្ច

ការអង្កេតនេះ មិនបានផ្តោតលើសូចនាករនានានៃអភិបាលកិច្ចដែលមាននៅក្នុងក្របខណ្ឌលទ្ធផលនោះទេ។ ជារួម សន្ទស្សន៍នៃការអង្កេតអភិបាលកិច្ច អាចបង្ហាញឲ្យឃើញមិនត្រឹមតែនិន្នាការទូទៅនៃអភិបាលកិច្ចនោះទេ ប៉ុន្តែសន្ទស្សន៍អភិបាលកិច្ចនីមួយៗ បានបង្ហាញនូវនិន្នាការតាមផ្នែកនីមួយៗនៃអភិបាលកិច្ច ឧទាហរណ៍៖ និន្នាការនៃការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ សន្ទស្សន៍នៃអភិបាលកិច្ចទាំងនោះត្រូវបានកំណត់នៅក្នុងផ.អ.៣ ដំណាក់កាលទី១ មានដូចខាងក្រោម៖

១. ការផ្តល់សេវា

២. បន្សុីគោលនយោបាយ

៣. ការឆ្លើយតប
៤. ការការពារ និងគាំទ្រក្រុមជនងាយរងគ្រោះ
៥. ការចូលរួមរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិល
៦. តម្លាភាព
៧. គណនេយ្យភាព
៨. ទំនាក់ទំនងរដ្ឋបាលថ្នាក់ក្រោមជាតិ

### ៤.៣. ដំណើរការ នៃការអង្កេតអភិបាលកិច្ច

ការអង្កេតអភិបាលកិច្ចគួរអនុវត្តជារៀងរាល់បីឆ្នាំម្តងស្របទៅនឹងក្របខណ្ឌរយៈពេលនៃផ.អ.៣ ឬនៅចុងឆ្នាំទី៣នៃផ.អ.៣ ដែលការវិភាគទិន្នន័យគួរធ្វើនៅខែធ្នូ ហើយរបាយការណ៍នៃការអង្កេតគួរត្រូវរៀបចំឡើងនៅឆ្នាំបន្ទាប់ និងគួរបញ្ចប់នៅត្រឹមខែមេសា។ តារាងខាងក្រោមនេះបង្ហាញពីជំហាននៃដំណើរការអង្កេត ហើយជំហាននីមួយៗនឹងត្រូវអនុវត្តដោយ គ.ជ.អ.ប ឬទីប្រឹក្សាដោយអាស្រ័យលើសមត្ថភាពរបស់បុគ្គលិកគ.ជ.អ.ប។ ការអង្កេតនេះអាចប្រព្រឹត្តទៅដោយមានការប្រឹក្សាយ៉ាងហោចណាស់លើផ្នែក៣សំខាន់ៗ ដូចជា៖

- ការប្រឹក្សាបច្ចេកទេស៖ (១).ការជ្រើសរើសសំណាក (២).ការកែសម្រួលបញ្ជីសំណួរ (៣).ការគណនា និងវិភាគផ្អែកលើទិន្នន័យនៃការអង្កេត
- ការប្រមូល និងបញ្ចូលទិន្នន័យទៅក្នុងកញ្ចប់កម្មវិធីវិទ្យាសាស្ត្រសង្គម(Social Science of software package)
- ការរៀបចំរបាយការណ៍នៃការអង្កេត

សកម្មភាពសំខាន់ៗសម្រាប់អនុវត្តការអង្កេតត្រូវបានសង្ខេបដូចខាងក្រោម៖

**តារាងទី៦ : ផែនការការងារសម្រាប់ការអង្កេតអភិបាលកិច្ច**

| ល.រ | សកម្មភាព | បរិយាយ |
|---|---|---|
| 1 | ដាក់បញ្ចូលការអង្កេតអភិបាលកិច្ចនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ | ដើម្បីធានាការអង្កេតមាននៅក្នុងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ។ការអង្កេតនេះអាចកំណត់ថាជាសកម្មភាពមួយ ឬបំបែកទៅជាសកម្មភាពតាមជំហានសំខាន់ៗ (ដូចជាការប្រមូលទិន្នន័យសម្រាប់ការអង្កេត និងការចងក្រងរបាយការណ៍នៃការអង្កេត) អាស្រ័យលើពេលវេលា ដើម្បីដាក់បញ្ចូលក្នុងផ.ស.ថប្រចាំឆ្នាំ |
| 2 | បង្កើតក្រុមការងារ និងពិនិត្យឡើងវិញនូវឯកសារពាក់ព័ន្ធទាំងអស់ | ក្រុមការងារមួយ គួរតែចាប់ផ្តើមពិនិត្យមើលឡើងវិញនូវវិធីសាស្ត្រ លទ្ធផលនៃការអង្កេតអភិបាលកិច្ចមុន និងឯកសារពាក់ព័ន្ធដទៃទៀត ដើម្បីជាមូលដ្ឋានក្នុងការអនុវត្តនូវការអង្កេត។ ហើយក្រុមការងារនេះ នឹងទទួលខុសត្រូវលើការរៀបចំឬពិនិត្យមើលនូវរបាយការណ៍នៃការអង្កេត។ |
| 3 | ជួបជាមួយភាគីពាក់ព័ន្ធដើម្បីកៀរគរ និងសម្រេចធនធានគាំទ្រដល់ការអង្កេតអភិបាលកិច្ច | រៀបចំនិងធ្វើបទបង្ហាញអំពីផែនការសម្រាប់ការអង្កេតទៅភាគីពាក់ព័ន្ធដើម្បីទទួលយកនូវមតិយោបល់ក្នុងការរៀបចំផែនការការងារអង្កេតនិងកៀរគរធនធាន |

| ល.រ | សកម្មភាព | បរិយាយ |
|---|---|---|
| 4 | ពិនិត្យមើលឡើងវិញ និងសម្រេចក្របខណ្ឌសំណាក | ក្របខណ្ឌសំណាក ត្រូវបានបរិយាយនៅក្នុងឯកសារវិធីសាស្ត្រអង្កេតអភិបាលកិច្ច |
| 5 | ពិនិត្យឡើងវិញ និងកែប្រែលក្ខខណ្ឌការងារនិងបញ្ជីសំណួរ | បញ្ជីសំណួរ នៃការអង្កេតអភិបាលកិច្ចមុន នឹងត្រូវពិនិត្យឡើងវិញ និងកែសម្រួលឲ្យកាន់តែប្រសើរឡើង ផ្អែកតាមយោបល់ដែលបានកត់ត្រានៅក្នុងឯកសារវិធីសាស្ត្រអង្កេតអភិបាលកិច្ច ។ |
| 6 | ដំណើរការលទ្ធកម្មជ្រើសរើសទីប្រឹក្សាប្រមូលទិន្នន័យ | លទ្ធកម្មអាចចំណាយពេលពីរខែ។ ចាំបាច់ត្រូវតាមដានជាមួយការិយាល័យលទ្ធកម្មនៃគ.ជ.អ.ប ដើម្បីកុំឲ្យមានភាពយឺតយ៉ាវ |
| 7 | ទីប្រឹក្សាធ្វើការប្រមូលទិន្នន័យ | |
| 8 | ចុះពិនិត្យនិងគាំទ្រដំណើរការនៃការប្រមូលទិន្នន័យរបស់ទីប្រឹក្សា | ការចុះត្រួតពិនិត្យមើលដំណើរការនៃការប្រមូលទិន្នន័យគឺជាកិច្ចការមួយចាំបាច់ដើម្បីធានាថាទីប្រឹក្សាបច្ចេកទេសកំពុងអនុវត្តការងារតាមការរំពឹងទុក និងធានាថាទិន្នន័យដែលប្រមូលបានគឺត្រឹមត្រូវ។ ការចុះពិនិត្យនិងគាំទ្រដំណើរការនៃការប្រមូលទិន្នន័យ ត្រូវបានបរិយាយក្នុងឯកសារវិធីសាស្ត្រអង្កេតអភិបាលកិច្ច ។ |
| 9 | ពិនិត្យមើលភាពពេញលេញ និងភាពត្រឹមត្រូវនៃទិន្នន័យ ដែលផ្តល់ដោយទីប្រឹក្សាបច្ចេកទេស | ទិន្នន័យដែលផ្តល់ដោយទីប្រឹក្សាបច្ចេកទេសត្រូវពិនិត្យយ៉ាងហ្មត់ចត់ ដើម្បីធានាថាទិន្នន័យមិនមានភាពខុសប្រក្រតី និងមានសង្គតិភាព។ ដំណើរការក្នុងការត្រួតពិនិត្យទិន្នន័យត្រូវបានអនុវត្តរយៈពេលយ៉ាងហោចណាស់២សប្តាហ៍។ |
| 10 | ពិនិត្យទិន្នន័យដែលផ្តល់ដោយទីប្រឹក្សាតាមរយៈការធ្វើតេស្តបែបស្ថិតិលើទិន្នន័យទាំងនោះ | ដូចបានរៀបរាប់នៅក្នុងឯកសារវិធីសាស្ត្រអង្កេត ស្ថិតិវិទ្យាអាចត្រូវបានប្រើប្រាស់ដើម្បីពិនិត្យមើលឯកត្តខ្វាត(outliers)។ ស្ថិតិវិទ្យាអាចបង្ហាញឲ្យដឹងថាការបញ្ចូលទិន្នន័យនោះមិនត្រឹមត្រូវ។ ការធ្វើតេស្តតាមបែបស្ថិតិគួរត្រូវធ្វើឡើងមុនពេលសម្រេចចិត្តចំណាយថវិកាទៅឲ្យទីប្រឹក្សា។ |
| 11 | ទិន្នន័យដែលបានសម្អាតរួចរាល់ត្រូវបានផ្តល់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប | កិច្ចសន្យាត្រូវការបញ្ជាក់ពីកាលបរិច្ឆេទច្បាស់លាស់សម្រាប់ការទទួលបានទិន្នន័យ |
| 12 | ពិនិត្យ សម្រេចលើទិន្នន័យ និងចំណាយថវិកាឲ្យទីប្រឹក្សាបច្ចេកទេស | បន្ទាប់ពីទិន្នន័យត្រូវបានពិនិត្យរួចរាល់ ទើបអាចចំណាយថវិកាទៅឲ្យទីប្រឹក្សា |

| ល.រ | សកម្មភាព | បរិយាយ |
|---|---|---|
| 13 | ស្រាវជ្រាវ និងពិនិត្យមើលការសិក្សាអភិបាលកិច្ចផ្សេងៗទៀតដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា | ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍផ្សេងទៀត និងស្វែងរកឯកសារអង្កេតអភិបាលកិច្ចផ្សេងៗទៀតលើបណ្តាញអ៊ិនធឺណេត |
| 14 | ការវិភាគទិន្នន័យតាមតារាងគំរូ(Formative data analysis) | ការអង្កេតអភិបាលកិច្ច នឹងត្រូវបង្កើតឲ្យមាននូវតារាងវិភាគទិន្នន័យ ឬគំរូគណនាសន្ទស្សន៍ ដើម្បីវិភាគទិន្នន័យ និងប្រៀបធៀបទិន្នន័យនៃការអង្កេតអភិបាលកិច្ចពីឆ្នាំមុនៗ |
| 15 | ការប្រើប្រាស់ទិន្នន័យបានផ្តល់សម្រាប់ធ្វើការគណនាមធ្យម អតិបរមា អប្បបរមា និងគម្លាតលម្អៀង | ការប្រើប្រាស់កញ្ចប់កម្មវិធីវិទ្យាសាស្ត្រសង្គម ដើម្បីវិភាគបែបស្ថិតិលើទិន្នន័យដែលបានសម្ភាសរួចរាល់។ រក្សាទុកលទ្ធផលវិភាគនៅក្នុងកម្មវិធី Microsoft MS. Excel សម្រាប់ការរៀបចំរបាយការណ៍ |
| 16 | ប្រើប្រាស់របាយការណ៍ និងការវិភាគនៃការអង្កេតអភិបាលកិច្ចពីឆ្នាំមុនៗដើម្បីវិភាគ និងផលិតទិន្នន័យ | ដូចបានរៀបរាប់ខាងលើ ការសរសេររបាយការណ៍នេះនឹងត្រូវផ្តោតសំខាន់លើទិន្នន័យដែលត្រូវការ។ ឧទាហរណ៍៖តារាងទិន្នន័យពីការអង្កេតឆ្នាំមុនៗបានបង្ហាញពីទិន្នន័យដែលត្រូវការ។ ហេតុដូច្នេះ ទិន្នន័យដែលត្រូវការកាន់តែមានភាពច្បាស់លាស់ តាមរយៈការពិនិត្យមើលនូវរបាយការណ៍ ឆ្នាំមុនៗ |
| 17 | ការវិភាគបែបស្ថិតិវិទ្យាលើសូចនាករ និងសន្ទស្សន៍នីមួយៗបានផ្លាស់ប្តូរចាប់តាំងពីការអង្កេតលើកទីមួយ | កិច្ចការនេះមិនដែលត្រូវបានធ្វើពីមុនទេ ប៉ុន្តែជាទូទៅតាមរយៈការប្រើគម្លាតស្តង់ដារសូចនាករមូលដ្ឋាននៃសន្ទស្សន៍តេស្តស្ថិតិចាំបាច់ត្រូវតែធ្វើដើម្បីសន្និដ្ឋានថាតើការប្រែប្រួលនៅក្នុងទិន្នន័យ។ |
| 18 | ការរៀបចំរបាយការណ៍ | ការរៀបចំរបាយការណ៍នៃអង្កេតអភិបាលកិច្ច ត្រូវចំណាយរយៈពេលប្រហែល១ ឬ២ខែ |
| 19 | ចែកចាយសេចក្តីព្រាងរបាយការណ៍ដើម្បីទទួលបានមតិយោបល់កែលម្អ | ផ្ញើសេចក្តីព្រាងរបាយការណ៍អង្កេតទៅដល់ដៃគូអភិវឌ្ឍសង្គមស៊ីវិល គ.ជ.អ.ប និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីទទួលបានមតិយោបល់កែលម្អ |
| 20 | រៀបចំបញ្ចប់សេចក្តីព្រាងរបាយការណ៍ | ផ្អែកលើមតិយោបល់នានាដែលទទួលបានពីអ្នកពាក់ព័ន្ធត្រូវកែសម្រួលឬបំពេញបន្ថែមនូវចំណុចខ្វះខាត ដើម្បីឲ្យបានគ្រប់ជ្រុងជ្រោយ |
| 21 | ការធ្វើបទបង្ហាញ | រៀបចំនិងធ្វើបទបង្ហាញសេចក្តីព្រាងរបាយការណ៍ដល់អ្នកពាក់ព័ន្ធ |
| 22 | ផ្សព្វផ្សាយរបាយការណ៍អង្កេតនៅលើគេហទំព័រគ.ជ.អ.ប | ផ្សព្វផ្សាយរបាយការណ៍ចុងក្រោយនៃការអង្កេតនៅលើគេហទំព័រគ.ជ.អ.បសម្រាប់សាធារណជន |

## ៤.៤. សមត្ថភាព នៃការរៀបចំរបាយការណ៍

ការរៀបចំរបាយការណ៍គឺជាការងារបច្ចេកទេសខ្ពស់មួយដែលទាមទារនូវពេលវេលាក្នុងការរៀបចំ។ បើទោះបីជាការប្រមូលទិន្នន័យ (ការសម្ភាសន៍ ការបញ្ចូលទិន្នន័យ) ត្រូវអនុវត្តតាមរយៈកិច្ចសន្យារយៈពេលខ្លី តែ គ.ជ.អ.ប ត្រូវ៖

- ពិនិត្យឡើងវិញនូវក្របខណ្ឌសំណាក លក្ខខណ្ឌការងារ និងបញ្ជីសំណួរ។ ការងារនេះត្រូវតែមានចំណេះដឹងលើផ្នែកស្ថិតិវិទ្យានិងការរៀបចំបញ្ជីសំណួរផងដែរ។
- ការងារវិភាគទិន្នន័យរួមមានការគណនាមធ្យម កម្រិតលម្អៀង រៀបចំនិងការវិភាគទិន្នន័យតាមបែបស្ថិតិស្របតាមក្របខណ្ឌពេលវេលា
- ពិនិត្យមើលលើសេចក្តីព្រាងរបាយការណ៍ និងសម្របសម្រួលការធ្វើបទបង្ហាញ

## ៤.៥. ការស្រាវជ្រាវ និងចែករំលែកទិន្នន័យនាពេលអនាគត

នៅក្នុងរបាយការណ៍ មានទិន្នន័យជាច្រើនដែលត្រូវបានបែងចែកតាមក្រុមផ្សេងៗ ជាឧទាហរណ៍៖ការបែងចែកក្រុមតាមយេនឌ័រនិងភាពក្រីក្រ។ ដោយសារទិន្នន័យអង្កេតពីមុនគ្របដណ្តប់តែ៩៦ឃុំ និង៤៨ក្រុង ស្រុក ខណ្ឌ ដែលមិនសមស្របសម្រាប់ការសន្និដ្ឋានដោយផ្អែកលើមូលហេតុ(causal inference)។

# ជំពូកទី៥
# ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ

## ៥.១. សេចក្តីផ្តើម

ការអភិវឌ្ឍសមត្ថភាពគឺជាផ្នែកមួយដ៏សំខាន់នៃកិច្ចខិតខំប្រឹងប្រែងរបស់គ.ជ.អ.ប ដើម្បីជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន ទទួលខុសត្រូវក្នុងការដឹកនាំ និងសម្របសម្រួលការវាយតម្លៃសមត្ថភាពឬការអភិវឌ្ឍសមត្ថភាព ដែលជាផ្នែកមួយនៃការអភិវឌ្ឍសមត្ថភាព ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធនានា ដូចជាអង្គភាពវិភាគនិងអភិវឌ្ឍគោលនយោបាយ។ ជាគោលការណ៍ ការវាយតម្លៃសមត្ថភាពឬការអភិវឌ្ឍសមត្ថភាពគួរតែត្រូវបានអនុវត្តជាទៀងទាត់។ នៅឆ្នាំ២០១១ គ.ជ.អ.បបានបង្កើតសៀវភៅណែនាំអំពីការវាយតម្លៃសមត្ថភាពរបស់ក្រុង ស្រុក ខណ្ឌ និងបានធ្វើការវាយតម្លៃសមត្ថភាពជាលើកដំបូងនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ សៀវភៅណែនាំអំពីការវាយតម្លៃសមត្ថភាពក្រុង ស្រុក ខណ្ឌ ក៏ពិពណ៌នាអំពីនីតិវិធីរបស់រដ្ឋបាលខេត្តក្នុងការវាយតម្លៃសមត្ថភាពក្រុង ស្រុក ខណ្ឌ និងបែបបទនៃការពិភាក្សា និងពិគ្រោះយោបល់អំពីការវាយតម្លៃសមត្ថភាព។ នីតិវិធីនេះត្រូវអនុវត្តដោយមានការគាំទ្រ ការកែលម្អ និងមានការសហការគ្នា ហើយមានគោលបំណងកំណត់ឧបសគ្គ និងផ្តល់អនុសាសន៍ ដើម្បីកែលម្អការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ សមាសភាពសំខាន់ៗនៃការវាយតម្លៃការអភិវឌ្ឍសមត្ថភាពត្រូវបានសង្ខេបដូចខាងក្រោម៖

- ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងជាលក្ខណៈពិភាក្សាដើម្បីកែលម្អការអនុវត្តការងារ។ សូចនាករនៃការវាយតម្លៃ ត្រូវបានរៀបចំឡើងដើម្បីកំណត់វិធីសាស្រ្តក្នុងការធ្វើឲ្យប្រសើរឡើងនូវការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ដំណើរការវាយតម្លៃការអភិវឌ្ឍសមត្ថភាពត្រូវបានអនុវត្ត និងចាត់ទុកជាផ្នែកមួយនៃការងារប្រចាំរបស់រដ្ឋបាលរាជធានី ខេត្ត
- កិច្ចពិភាក្សានេះ ជាកិច្ចពិភាក្សាប្រកបដោយការចូលរួម ដោយផ្អែកលើភស្តុតាង និងការបកស្រាយនៃសូចនាករ និងបញ្ជីត្រួតពិនិត្យនានា
- សូចនាករនៃការវាយតម្លៃ ជាសូចនាករដែលមានគោលបំណងជាក់លាក់ និងអាចផ្ទៀងផ្ទាត់បាន
- ការវាយតម្លៃសមត្ថភាពនិងសូចនាករត្រូវបានរៀបចំដោយយោងទៅតាមមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សូចនាករដែលមានពិន្ទុនិងបញ្ជីត្រួតពិនិត្យ នឹងត្រូវបានគណនាតាមសន្ទស្សន៍ និងបូកសរុប តាមមុខងារ និងអង្គភាពនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវលើមុខងារនីមួយៗ
- ការវាយតម្លៃក៏គ្របដណ្តប់លើថាតើមុខងារដែលបានកំណត់នានាត្រូវបានអនុវត្តនាពេលបច្ចុប្បន្នដែរឬទេ ពោលគឺសំដៅលើកម្រិតសមត្ថភាពដែលចាំបាច់ក្នុងការអនុវត្តមុខងារ ឬក៏មានសមត្ថភាពកម្រិតទាបដែលជាឧបសគ្គក្នុងការអនុវត្តមុខងាររបស់ខ្លួន
- ការរៀបចំការវាយតម្លៃ និងដំណើរការពិភាក្សាត្រូវបានរំពឹងថានឹងត្រូវបានកែសម្រួល និងអភិវឌ្ឍជាបន្តបន្ទាប់
- ក្នុងពេលអនាគត មុខងារអាចត្រូវបានពង្រីកបន្ថែម ហើយនៅពេលនោះគោលការណ៍ណែនាំ និងសៀវភៅណែនាំស្តីពីការវាយតម្លៃសមត្ថភាព នឹងត្រូវបានរៀបចំឡើងជាស្តង់ដារជាក់លាក់មួយ។ ហើយកិច្ចការនេះ បង្ហាញកាន់តែច្បាស់លាស់នូវលទ្ធផលរំពឹងទុករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ហើយស្តង់ដារនេះនឹងត្រូវបានប្រើប្រាស់ដើម្បីកែលម្អសូចនាករ និងបញ្ជីតាមដាន។
- ការវាយតម្លៃនេះមានគោលបំណងគាំទ្រដល់ដំណើរការអភិវឌ្ឍស្ថាប័ន ដែលការអភិវឌ្ឍស្ថាប័ននឹងត្រូវបានពិនិត្យមើលឡើងវិញនិងកែលម្អឲ្យកាន់តែប្រសើរឡើង ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ

➢ ដំណើរការនេះគឺផ្អែកលើភស្តុតាង ដូចជា"មធ្យោបាយផ្ទៀងផ្ទាត់" និងផ្អែកលើមុខងារនិងការរំពឹងទុកដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត

ឯកសារសំខាន់ៗពាក់ព័ន្ធនឹងការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌមានដូចខាងក្រោម៖

- សៀវភៅណែនាំស្តីពីការវាយតម្លៃសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១១
- សៀវភៅណែនាំស្តីពីការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១២
- របាយការណ៍វាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌឆ្នាំ២០១១ និងឆ្នាំ២០១៣
- របាយការណ៍ស្តីពីការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៧
- យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរបស់ជ.អ.៣
- ក្របខណ្ឌលទ្ធផលរបស់ជ.អ.៣

## ៥.២. ដំណើរការវាយតម្លៃការអភិវឌ្ឍសមត្ថភាព

ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានអនុវត្តដូចខាងក្រោម៖

- រៀបចំ ពិនិត្យឡើងវិញ និងកែសម្រួលសូចនាករ និងចងក្រង បញ្ចូលសូចនាករទាំងនេះទៅក្នុងប្រព័ន្ធទិន្នន័យ
- ពិនិត្យនិងកែសម្រួលទម្រង់ទិន្នន័យ
- បណ្តុះបណ្តាលបុគ្គលិកក្នុងការវាយតម្លៃការអភិវឌ្ឍសមត្ថភាព
- ប្រមូលទិន្នន័យ និងបញ្ចូលទិន្នន័យទៅក្នុង Excel
- ទាញទិន្នន័យចូលទៅក្នុងប្រព័ន្ធទិន្នន័យ
- វាយតម្លៃគុណភាពទិន្នន័យ ពិនិត្យឡើងវិញនិងកែសម្រួលទិន្នន័យចុងក្រោយ
- រៀបចំរបាយការណ៍

## ៥.៣. ការពិនិត្យសូចនាករឡើងវិញ

នៅចុងឆ្នាំ សូចនាករត្រូវតែពិនិត្យ និងកែសម្រួលឡើងវិញ ហើយការពិនិត្យឡើងវិញយ៉ាងស៊ីជម្រៅនឹងត្រូវធ្វើឡើងប្រសិនបើមុខងារមួយចំនួនទៀតត្រូវបានផ្ទេរឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ សូចនាករ គួរត្រូវបានកាត់បន្ថយ ដើម្បីបង្កើនការពិគ្រោះយោបល់បន្ថែមទៀតលើការអភិវឌ្ឍសមត្ថភាព និងបង្កើនគុណភាពទិន្នន័យដែលប្រមូលបាន។ ការពិនិត្យមើលឡើងវិញនូវសូចនាកររួមមានដូចខាងក្រោម៖

១. កំណត់សូចនាករមុខងារ (ពិពណ៌នានៅក្នុងសៀវភៅណែនាំស្តីពីការវាយតម្លៃសមត្ថភាព) និងកំណត់របៀបគណនាសន្ទស្សន៍ដោយស្វ័យប្រវត្តិ

២. កំណត់ទម្រង់សូចនាករ។ ទម្រង់សូចនាករ (និងលេខកូដ) នឹងកំណត់អ្នកទទួលខុសត្រូវក្នុងការប្រមូលសូចនាករ។ ការកំណត់នូវលេខកូដផ្អែកអភិវឌ្ឍសមត្ថភាពទៅតាមសូចនាករនីមួយៗ ទាមទារផ្លាស់ប្តូរដោយស្វ័យប្រវត្តិពីឯកសារបែបExcel ទៅជា Access

## ៥.៤. ការកែសម្រួលទម្រង់កម្មវិធីអង្កេត

សន្ទស្សន៍និងសូចនាករ ត្រូវបានកំណត់ ហើយទម្រង់ទិន្នន័យត្រូវបានបោះពុម្ពចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ។ ព័ត៌មានទាំងអស់នេះគួរត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីអង្កេត(Survey Software)។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១២ ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពត្រូវបានប្រើប្រាស់កម្មវិធីអង្កេតមួយមានឈ្មោះថា "Lime survey" ។ បញ្ជីសូចនាករទាំងអស់តាមទម្រង់នីមួយៗ ត្រូវបានបំលែងទៅក្នុងប្រព័ន្ធកុំព្យូទ័រ។

## ៥.៥. ការបណ្តុះបណ្តាល

នៅពេលសូចនាករត្រូវបានរៀបចំនិងកម្មវិធីសម្រាប់ការអង្កេតបានធ្វើបច្ចុប្បន្នភាពរួចរាល់ វគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានរៀបចំឡើង។ កិច្ចការនេះគួរធ្វើនៅដើមឆ្នាំ (នៅ

អំឡុងខែមករា)។ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន ទទួលខុសត្រូវក្នុងការរៀបចំឯកសារបណ្ដុះបណ្ដាល និងផ្ដល់វគ្គបណ្ដុះបណ្ដាល។

## ៥.៦. ការប្រមូល និងបញ្ចូលទិន្នន័យ

រដ្ឋបាលរាជធានី ខេត្តទទួលខុសត្រូវក្នុងការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ទោះជាយ៉ាងនេះក្ដី ការបញ្ចូលទិន្នន័យធ្វើឡើងតាមកម្រិតរដ្ឋបាលនីមួយៗ។ ឧទាហរណ៍៖ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗនឹងត្រូវបញ្ចូលទិន្នន័យគ្រប់ទម្រង់។ ទម្រង់វាយតម្លៃទាំងនោះមានរៀបរាប់ដូចខាងក្រោម៖

- ទម្រង់បញ្ជីសំណួរសម្រាប់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ទម្រង់បញ្ជីសំណួរសម្រាប់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ទម្រង់បញ្ជីសំណួរសម្រាប់នាយក នាយករងរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ទម្រង់បញ្ជីសំណួរសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សា និងវេទិកាសាធារណៈ
- ទម្រង់បញ្ជីសំណួរសម្រាប់គណៈអភិបាលក្រុង ស្រុក ខណ្ឌ
- ទម្រង់បញ្ជីសំណួរសម្រាប់ផ្នែកហិរញ្ញវត្ថុនៃការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ
- ទម្រង់បញ្ជីសំណួរសម្រាប់ផ្នែករដ្ឋបាលនៃការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ
- ទម្រង់បញ្ជីសំណួរសម្រាប់ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក
- ទម្រង់បញ្ជីសំណួរសម្រាប់ការិយាល័យអន្តរវិស័យនៃរដ្ឋបាលស្រុក ខណ្ឌ និងការិយាល័យអភិវឌ្ឍក្រុងនៃរដ្ឋបាលក្រុង
- ទម្រង់បញ្ជីសំណួរសម្រាប់បុគ្គលិកម្នាក់ៗ
- ទម្រង់បញ្ជីសំណួរសម្រាប់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់
- ទម្រង់បញ្ជីសំណួរសម្រាប់ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារ
- ទម្រង់បញ្ជីសំណួរសម្រាប់វាយតម្លៃក្រុមការងាររដ្ឋបាលរាជធានី ខេត្ត
- ទម្រង់បញ្ជីសំណួរសម្រាប់ការិយាល័យច្រកចេញចូលតែមួយ

សូចនាករនីមួយៗនៅក្នុងទម្រង់ត្រូវតែមានលេខកូដភ្ជាប់មកជាមួយ។ ហើយលេខកូដនេះត្រូវតែដាក់ថា "CD Unit IDs" នៅក្នុងកម្មវិធីអង្កេត។ កូដទម្រង់នីមួយៗត្រូវបានពិពណ៌នាយ៉ាងលម្អិតនៅក្នុងឯកសារណែនាំស្ដីពីកម្មវិធីអង្កេត។ នៅពេលរដ្ឋបាលក្រុង ស្រុក ខណ្ឌបញ្ចូលទិន្នន័យ ទិន្នន័យទាំងនោះនឹងត្រូវបានរក្សាទុកនៅក្នុងកុំព្យូទ័ររបស់ពួកគេ ហើយបន្ទាប់មកទៀតត្រូវបានផ្ញើចេញ(ដោយស្វ័យប្រវត្តិ)ទៅក្នុងម៉ាស៊ីនមេរបស់គ.ជ.អ.ប។ នៅពេលដែលទិន្នន័យត្រូវបានបញ្ចូលចប់សព្វគ្រប់ (ដូចជា គ្រប់ទម្រង់ និងគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ត្រូវបានបញ្ចូលទិន្នន័យរួចរាល់) តារាងទិន្នន័យសម្រាប់ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវផ្ញើជូនអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន។ ហើយតារាងទិន្នន័យនីមួយៗ ត្រូវមាន៖

- ត្រូវដាក់ឈ្មោះជា FORM 1, 2, 12 (ទម្រង់ទី១ ទី២ ឬទី១២)
- ត្រូវចម្លងទុកទិន្នន័យដើមដើម្បីរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យ។ ហើយទម្រង់អង្កេតឆ្នាំមុនៗត្រូវរក្សាទុកនៅកន្លែងផ្សេង ព្រោះកម្មវិធីនឹងអានដោយស្វ័យប្រវត្តិនូវរាល់តារាងExcel ទាំងអស់នៅក្នុងកន្លែងរក្សាទិន្នន័យ និងផ្ដើមដោយបួនអក្សរគឺ"FORM"។

នៅពេលដែលទម្រង់ទាំងអស់ត្រូវបានចម្លងទុកនិងរក្សាទុកក្នុងប្រព័ន្ធទិន្នន័យត្រឹមត្រូវហើយ ទិន្នន័យអាចត្រូវបានយកទៅវិភាគនៅក្នុងប្រព័ន្ធទិន្នន័យ(សូមមើលសៀវភៅណែនាំបន្ថែម)។

## ៥.៧. ការទាញទិន្នន័យនៅក្នុងប្រព័ន្ធទិន្នន័យ

ដើម្បីធានានូវគុណភាពទិន្នន័យ និងកាត់បន្ថយឯកត្តខ្វាតរបស់ទិន្នន័យជាមុន ចាំបាច់ត្រូវទាញទិន្នន័យចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ នៅពេលទាញទិន្នន័យចូលក្នុងប្រព័ន្ធហើយ ត្រូវពិនិត្យនិងផ្ទៀងផ្ទាត់នូវទិន្នន័យ

ទាំងនោះ ដើម្បីកាត់បន្ថយកំហុសដោយអចេតនារបស់អ្នកបញ្ចូលទិន្នន័យ និងភាពលម្អៀងនៃទិន្នន័យនីមួយៗ។ ប្រសិនបើទិន្នន័យទាំងនោះពិនិត្យទៅមានភាពមិនប្រក្រតី អ្នកគួរត្រូវអនុវត្តនូវជំហានដូចខាងក្រោម៖

១.ក្នុងករណីទិន្នន័យមានភាពមិនប្រក្រតីខ្លាំង ត្រូវទំនាក់ទំនងទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីស្នើឲ្យមានការកែតម្រូវ។ វិធីនេះ ចំណាយពេលវេលាច្រើន ដូចនេះករណីនេះធ្វើឡើងតែពេលដែលទិន្នន័យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានភាពខុសប្រក្រតីធ្ងន់ធ្ងរ។ ករណីភាគច្រើន គេមិនអាចកំណត់ឯកត្តខ្នាត តាមរយៈទូរស័ព្ទបានទេ។

២.កែសម្រួលវិធីសាស្ត្រផ្ទៀងផ្ទាត់ទិន្នន័យក្នុងប្រព័ន្ធទិន្នន័យ ដើម្បីលុបទិន្នន័យមិនត្រឹមត្រូវចោល

៣.នៅពេលទិន្នន័យឬវិធីសាស្ត្រផ្ទៀងផ្ទាត់ទិន្នន័យត្រូវបានផ្លាស់ប្តូរ ទាមទារឲ្យមានការកែសម្រួលទិន្នន័យឡើងវិញក្នុងប្រព័ន្ធទិន្នន័យ ដើម្បីកែសម្រួលភាពមិនត្រឹមត្រូវ។

## ៥.៨. ការរៀបចំរបាយការណ៍

កម្មវិធី(software) ត្រូវបានប្រើប្រាស់ ដើម្បីផលិតជារបាយការណ៍សំខាន់ៗពីប្រព័ន្ធទិន្នន័យនោះ។ ដូចដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំស្តីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទិន្នន័យអាចត្រូវបាននាំចេញទៅកាន់កម្មវិធីExcelកាន់តែងាយស្រួល។ ក្នុងន័យនេះ របាយការណ៍ត្រូវបានរៀបចំតាមវិធីពីរយ៉ាង៖

១. របាយការណ៍ផ្តោតលើលទ្ធផលរំពឹងទុក ត្រូវបានបោះពុម្ពចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងត្រូវបានប្រើប្រាស់សម្រាប់រៀបចំ"របាយការណ៍វាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ"។

២. ដូចដែលបានរៀបរាប់ពីខាងដើម ដើម្បីកាត់បន្ថយពេលវេលា និងធនធានក្នុងការរៀបចំរបាយការណ៍វាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌនាពេលអនាគត គួរតែរៀបចំរបាយការណ៍ខ្លី ដោយភ្ជាប់ទិន្នន័យពាក់ព័ន្ធទៅនឹងរបាយការណ៍នោះ ជាជាងរៀបចំជារបាយការណ៍វែងពេក។

# ជំពូកទី៦

# ការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ

## ៦.១. សេចក្តីផ្តើម

សៀវភៅណែនាំស្តីពី "ការត្រួតពិនិត្យនិងវាយតម្លៃគោលនយោបាយ" ពិពណ៌នាអំពីនីតិវិធីដែលលេខាធិការដ្ឋាន គ.ជ.អ.ប ត្រួតពិនិត្យនិងវាយតម្លៃគោលនយោបាយ ព្រមទាំងពិពណ៌នាអំពីដំណើរការ និងឧបករណ៍ដែលត្រូវប្រើប្រាស់ក៏ដូចជាផែនការសកម្មភាព និងការទទួលខុសត្រូវរបស់ស្ថាប័នក្នុងការត្រួតពិនិត្យនិងវាយតម្លៃគោលនយោបាយ។ គោលនយោបាយ ត្រូវបានផ្តល់និយមន័យដូចខាងក្រោម៖

**"សេចក្តីសម្រេចចិត្ត គោលការណ៍ ឬសកម្មភាពប្រកបដោយគោលដៅ និងសង្គតិភាព: (១)ដែលត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមជាក់ស្តែង (២)ដែលត្រូវបានដាក់ចេញដោយដំណើរការនៃនយោបាយជាក់លាក់ (៣)ត្រូវបានអនុម័ត អនុវត្ត និងពង្រឹងការអនុវត្ត ដោយស្ថាប័នឬអង្គភាពសាធារណៈ"។**

## ៦.២. ក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ

សៀវភៅណែនាំនេះ ត្រូវកំណត់និងពិពណ៌នាយ៉ាងលម្អិតអំពីឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយចំនួន១២ផ្សេងគ្នា ដោយប្រើប្រាស់វិធីសាស្ត្រចម្រុះគ្នាទាំងបែបបរិមាណ និងគុណភាព ដូចបង្ហាញខាងក្រោម៖

### ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ



## ៦.៣. ផែនការសកម្មភាពត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ

ការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយគឺជាសកម្មភាពរយៈពេលវែង។ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន ត្រូវតែសហការគ្នាយ៉ាងជិតស្និទ្ធជាមួយអង្គភាពវិភាគនិងអភិវឌ្ឍគោលនយោបាយក្នុងការអនុវត្ត ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃទាំងនេះបន្តិចម្តងៗ។ ម្យ៉ាងវិញទៀត ជារៀងរាល់ឆ្នាំ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន ត្រូវពិគ្រោះយោបល់និងសហការជាមួយនឹងអង្គភាពវិភាគនិងអភិវឌ្ឍគោលនយោបាយ ដើម្បីរៀបចំផែនការសកម្មភាពត្រួតពិនិត្យនិងវាយតម្លៃ និងកំណត់អាទិភាពនៃលិខិតបទដ្ឋានគតិយុត្តដែលត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃ។

# ជំពូកទី៧
# ការវាយតម្លៃផលប៉ះពាល់

## ៧.១. សេចក្តីផ្តើម

ការវាយតម្លៃផលប៉ះពាល់គឺជាការអង្កេតទៅលើមូលហេតុ។ គ.ជ.អ.ប នឹងសាកសួរសំណួរដើម្បីវាយតម្លៃផលប៉ះពាល់ នៅពេលដែលចង់ដឹងថា តើ ជ.អ.៣ មានប្រសិទ្ធភាពដែរឬទេ? ហើយលទ្ធផលរំពឹងទុកនៃជ.អ.៣ ជះឥទ្ធិពលដល់សមិទ្ធផលរំពឹងទុកដែរឬទេ? ផលប៉ះពាល់គឺជាការផ្លាស់ប្តូរទៅលើអ្វីមួយ (អថេរមួយ) បណ្តាលមកពីអ្វីមួយផ្សេងទៀត។

**ផលប៉ះពាល់** គឺជាការផ្លាស់ប្តូរមួយដែលបណ្តាលមកពីកិច្ចអន្តរាគមន៍ណាមួយ ហើយផលប៉ះពាល់នៃកិច្ចអន្តរាគមន៍នោះ អាចជាវិជ្ជមានឬអវិជ្ជមាន មានបំណងឬគ្មានបំណង។

ការវាយតម្លៃផលប៉ះពាល់ ត្រូវបានអនុវត្តតាមរយៈការប្រៀបធៀបសមិទ្ធផលរំពឹងទុកនៃក្រុមមួយ (មនុស្ស សហគមន៍ ឬអង្គការ) ដែលទទួលបានពីការអនុវត្តកម្មវិធី ជាមួយនឹងក្រុមមួយទៀតដែលមិនទទួលបានពីការអនុវត្តកម្មវិធី។ កិច្ចអន្តរាគមន៍(លទ្ធផលរំពឹងទុក កម្មវិធី គោលនយោបាយ) គឺជាអ្វីដែលយើងបានធ្វើ ហើយសមិទ្ធផលរំពឹងទុកគឺជាការផ្លាស់ប្តូរនៃលទ្ធផល។ លទ្ធផលរំពឹងទុក មានការចំណាយ (ពេលវេលា និងធនធាន) ហើយសមិទ្ធផលរំពឹងទុកគឺជាផលដែលទទួលបាន។ តាមទ្រឹស្តីគណិតវិទ្យា លទ្ធផលរំពឹងទុកជាអថេរឯករាជ្យមួយ ខណៈដែលសមិទ្ធផលគឺជាអថេរមិនឯករាជ្យឬអាស្រ័យផល។ ផលប៉ះពាល់កើតឡើងនៅពេលA បណ្តាលឲ្យB (តាង A-B)។ ឧទាហរណ៍៖តើការអនុវត្តមូលនិធិឃុំ សង្កាត់(A) បណ្តាលឲ្យកាត់បន្ថយភាព ក្រីក្រ(B) ដែរឬទេ? ឬ តើជ.អ.៣ (A)ពង្រឹងអភិបាលកិច្ចមូលដ្ឋាន(B) ដែរឬទេ? ទំនាក់ទំនង(ការអង្កេតថាតើអថេរពីរមានការផ្លាស់ប្តូរជាមួយគ្នាដែរឬទេ)មិនដូចគ្នានឹងមូលហេតុទេ។ ទោះបី (A) (B) អាចនឹងមានទំនាក់ទំនងគ្នា ប៉ុន្តែការសន្និដ្ឋានដោយផ្អែកលើមូលហេតុ (causal inference) ត្រូវ៖(i) សន្និដ្ឋានថាBមិនមែនបណ្តាលឲ្យ Aវិញទេ (ii)សន្និដ្ឋានថាការផ្លាស់ប្តូរនៃB មិនមែនបណ្តាលមកពីអថេរទី៣ឬអថេរដែលមិនបានអង្កេតទេ(C) និង (iii) មិនគិតដល់លទ្ធផលកើតឡើងដោយសារតែវិធីសាស្ត្រជ្រើសរើសសំណាកនោះទេ (ឧទាហរណ៍៖ ធានាថាទំនាក់ទំនងនោះមានភាពទូទៅ)។ នៅក្នុងការអនុវត្តជាក់ស្តែង មានការលំបាកខ្លាំងណាស់ ក្នុងការសម្រេចបាននូវលក្ខខណ្ឌទាំងបីនេះ។

ផលប៉ះពាល់គឺជាភាពខុសគ្នារវាងការផ្លាស់ប្តូរដែលបានកើតឡើងនិងកិច្ចអន្តរាគមន៍ ហើយការផ្លាស់ប្តូរអាចនឹងកើតឡើង ទោះបីជាគ្មានកិច្ចអន្តរាគមន៍។ នេះត្រូវបានគេហៅថាការប្រឆាំងនឹងអង្គហេតុ (counter-factual)។ តាមទ្រឹស្តី ការប្រឆាំងនឹងអង្គហេតុ(អ្វីដែលនឹងកើតឡើង) ត្រូវបានបង្កើតឡើងតាមរយៈបច្ចេកទេសពិសោធន៍ដែលអាចកើតឡើងនៅក្នុងមន្ទីរពិសោធន៍។ នេះជាដំណើរការមួយត្រូវបានប្រើប្រាស់នៅក្នុងការធ្វើតេស្តថ្នាំ ដែលអ្នកជំងឺត្រូវបានជ្រើសរើសដោយចៃដន្យ ដើម្បីចាត់ចូលទៅក្នុងក្រុមពិសោធន៍(ទទួលថ្នាំមានសារធាតុព្យាបាល) និងក្រុមមិនមែនពិសោធន៍ (ទទួលថ្នាំដែលមិនមានសារធាតុព្យាបាល)។ វិធីសាស្ត្រភាពខុសគ្នានៃភាពខុសគ្នា (A difference of differences គឺប្រៀបធៀបរវាងមុនពេលនិងក្រោយពេលពិសោធន៍ ព្រមទាំងប្រៀបធៀបរវាងក្រុមពិសោធន៍ និងក្រុមមិនមែនពិសោធន៍) ត្រូវបានប្រើប្រាស់ក្នុងការវាស់វែងផល ប៉ះពាល់បន្ទាប់បន្សំនៃការព្យាបាល (marginal impact of the treatment) ។ សេណារីយ៉ូមុននិងក្រោយ ពេលពិសោធន៍ ត្រូវបានប្រើប្រាស់ ដើម្បីកំណត់អថេរដែលមិនត្រូវបានអង្កេតទាំងអស់ដែលអាចមាន។

ការវិភាគបែបតម្លៃនិងផលប្រយោជន៍រួម (Summative cost-benefit) មិនអាចអនុវត្តបានទេ បើគ្មានការវាស់វែងជាបឋមលើផលប៉ះពាល់បន្ទាប់បន្សំ តាមរយៈការវាយតម្លៃផលប៉ះពាល់នោះទេ។

## ៧.២. ដំណើរការនៃការវាយតម្លៃផលប៉ះពាល់

នៅក្នុងដំណើរការនៃការវាយតម្លៃមួយ ដោយសារទ្រឹស្តីប្រឆាំងនឹងអង្គហេតុមិនអាចត្រូវបានអង្កេតដោយផ្ទាល់ (ដោយសារវាមិនអាចកើតមាន) ដូចនេះទ្រឹស្តីប្រឆាំងនឹងអង្គហេតុ ត្រូវបានគណនាឬអនុវត្តដោយប្រើប្រាស់បច្ចេកទេសពិសោធន៍ ឬស្ទើរពិសោធន៍នានា។ នៅក្នុងបច្ចេកទេសពិសោធន៍ ទិន្នន័យត្រូវបានបង្កើតឡើងដែលជាផ្នែកមួយនៃប្លង់ពិសោធន៍ដោយចៃដន្យជាក្រុមមនុស្ស (ឬអង្គការ ឬអង្គភាពមួយនៃការ សង្កេត) ចូលទៅក្នុងក្រុមពិសោធន៍(treatment group) និងក្រុមមិនមែនពិសោធន៍(control group)។

បច្ចេកទេសពិសោធន៍ចៃដន្យអាចត្រូវបានប្រើប្រាស់នៅក្នុងជ.អ.៣ ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ ឬ ក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់ចូលទៅក្នុងក្រុមផ្សេងៗគ្នាដោយចៃដន្យ ប៉ុន្តែវិធីសាស្ត្រនេះមិនត្រូវប្រើប្រាស់នោះទេ។

នៅក្នុងការធ្វើប្លង់ពិសោធន៍ (experimental design) ក្រុមពិសោធន៍ និងក្រុមមិនមែនពិសោធន៍ ត្រូវបានគេស្គាល់(និងពិត) ខណៈការរៀបចំប្លង់ស្ទើរពិសោធន៍(quasi-experimental design) ក្នុងក្រុមពិសោធន៍ និងក្រុមមិនមែនពិសោធន៍ ត្រូវបានបង្កើតតាមបែបស្ថិតិវិទ្យា។

**តារាងទី៧៖ វិធីសាស្ត្រវាយតម្លៃផលប៉ះពាល់**

| ប្រភេទការវាយតម្លៃ | វិធីសាស្ត្រ | ទិដ្ឋភាពទូទៅ |
|---|---|---|
| ប្លង់ពិសោធន៍ (Experimental Design) | ប្លង់ពិសោធន៍ចៃដន្យ (Randomized design) | ការវាយតម្លៃនេះពាក់ព័ន្ធនឹងប្លង់ពិសោធន៍ត្រូវរៀបចំនូវក្រុមមនុស្សឬគ្រួសារដែលអ្នកទទួលផលក្នុងគម្រោង ឬក្រុមមិនមែនពិសោធន៍ ដែលមិនទទួលបានសេវា ឬសម្ភារៈដែលផ្តល់ឲ្យដោយគម្រោង។ |
| ប្លង់ស្ទើរពិសោធន៍ (Quasi-experimental design) | សមីការនិទស្សភាព (Regressions) ហើយ ឧបករណ៍មានអថេរ និង វិធីសាស្ត្រស្ថិតិវិទ្យាដទៃទៀត | វិធីសាស្ត្រនេះទាក់ទងនឹងការជ្រើសរើសក្រុមមិនមែនពិសោធន៍មិនស្មើគ្នា(non-equivalent control group) ដើម្បីផ្គូរផ្គងយ៉ាងជិតស្និទ្ធនឹងប្រជាសាស្ត្រគម្រោង តាមរយៈការកែសម្រួលពិន្ទុត្រូវប្រើប្រាស់វិធីសាស្ត្រសមីការពហុនិទស្សភាព (multivariate regression approach)។ វិធីសាស្ត្រនេះត្រូវបានគេប្រើជាញឹកញាប់ទាក់ទងនឹងការអង្កេតទ្រង់ទ្រាយធំៗ និងការវិភាគស្ថិតិវិទ្យាទំនើប។ |

## ៧.៣. ទិន្នន័យនិងម៉ូឌែល នៃផលប៉ះពាល់

ម៉ូដែលនេះ ត្រូវបានប្រើប្រាស់ ដើម្បីសួរសំណួរអំពីផលប៉ះពាល់។ សូចនាករគឺជាអញ្ញត្តិដែលត្រូវបានប្រើប្រាស់ ដើម្បីវាស់ "A's" និង "B's" នៅក្នុងម៉ូឌែលនៃមូលហេតុ (A-B) ។ ក្នុងឧទាហរណ៍ខាងលើ សម្មតិកម្មដែលយើងចង់សាកល្បងគឺថាតើមូលនិធិឃុំ សង្កាត់នឹងកាត់បន្ថយភាពក្រីក្រដែរឬទេ។ សូចនាករនៃកម្រិតនៃការផ្តល់មូលនិធិឃុំ សង្កាត់អាចជា "ការផ្តល់មូលនិធិឃុំ សង្កាត់ជាមធ្យម ក្នុងមនុស្សម្នាក់ គិតជាដុល្លារ" ខណៈពេលដែលសូចនាករនៃភាពក្រីក្រអាចជា "GDPក្នុងមនុស្សម្នាក់" ឬ"ភាគរយប្រជាជនដែលស្ថិតនៅក្រោម

ខ្សែបន្ទាត់ភាពក្រីក្រ"។ ក្របខណ្ឌលទ្ធផលជ.អ.៣បានកំណត់លទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជា ៣ កម្រិតឬប្រភេទ (លទ្ធផលរំពឹងទុក សមិទ្ធផលរំពឹងទុក [លទ្ធផលនៅកម្រិតថ្នាក់ក្រោមជាតិ] និងផលប៉ះពាល់[លទ្ធផលនៅកម្រិតប្រជាជន]) ក៏ដូចជាសូចនាករជាច្រើនដែលអាចត្រូវបានប្រើប្រាស់ ដើម្បីវាយតម្លៃនេះផងដែរ។

នៅក្នុងម៉ូឌែលជ.អ.៣៖

- លទ្ធផលរំពឹងទុកគឺសមត្ថភាពបុគ្គលិក អង្គភាព និងស្ថាប័នដែលបានពង្រឹង ហើយការពង្រឹងសមត្ថភាពស្ថាប័នត្រូវបានអនុវត្តដើម្បីធ្វើឲ្យប្រសើរឡើងនូវស្វ័យភាពសារពើពន្ធ ការងាររដ្ឋបាល និងនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សមិទ្ធផលរំពឹងទុកគឺជាការលើកកម្ពស់មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ។ នៅក្នុងតារាងខាងក្រោមបង្ហាញពីលទ្ធផលសំខាន់ៗមួយចំនួននិងទិន្នន័យដែលអាចរកបាន ដូចខាងក្រោម៖

### តារាងទី៤៖ ទិន្នន័យដែលអាចរកបាន

| ប្រភេទសូចនាករ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត | ក្រសួង ស្ថាប័ន |
|---|---|---|---|---|
| 1. ជាតុចូល | | | | |
| ការចំណាយ/មូលនិធិ | ខ្លះ | ខ្លះ | ខ្លះ | ក្រសួងសេដ្ឋកិច្ច និងមន្ទីរនានា |
| ចំណាយលើបុគ្គលិកក្នុងមួយនាក់ | | ខ្លះ | ខ្លះ | ទិន្នន័យក្រសួងមហាផ្ទៃ និង ក្រសួងមុខងារសាធារណៈ |
| 2. សមត្ថភាព | N/A | មាន | មាន | ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពដោយគ.ជ.អ.ប |
| 3. កម្រិតស្វ័យភាព | | | | |
| សារពើពន្ធ | ខ្លះ | ខ្លះ | N/A | ក្រសួងសេដ្ឋកិច្ច |
| ការគ្រប់គ្រងហិរញ្ញវត្ថុ | មាន | មាន | មាន | ក្រសួងសេដ្ឋកិច្ច |
| ការគ្រប់គ្រងធនធានមនុស្ស | | មាន | មាន | ក្រសួងមហាផ្ទៃ និង ក្រសួងមុខងារសាធារណៈ |
| នយោបាយ | មាន | មាន | មាន | ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| ការប្រគល់មុខងារ | ខ្លះ | ខ្លះ | ខ្លះ | គ.ជ.អ.ប និងមន្ទីរនានា |
| 4. អភិបាលកិច្ច | | | | |
| ការអង្កេតអភិបាលកិច្ច | ខ្លះ | ខ្លះ | N/A | ការអង្កេតអភិបាលកិច្ច ដោយគ.ជ.អ.ប |
| ទិន្នន័យរដ្ឋបាល | N/A | ខ្លះ | N/A | ប្រព័ន្ធព័ត៌មានគ្រប់គ្រងរបស់គ.ជ.អ.ប |
| ទិន្នន័យអនុលោមភាព (Compliance data) | N/A | N/A | N/A | ក្រសួងមហាផ្ទៃ |
| 5. កម្រិតផ្តល់សេវា | | | | |
| គម្រោងហេដ្ឋារចនាសម្ព័ន្ធ | មាន | ខ្លះ | N/A | ប្រព័ន្ធព័ត៌មានទិន្នន័យនៃការអនុវត្តគម្រោងរបស់គ.ជ.អ.ប |

| ប្រភេទសូចនាករ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត | ក្រសួង ស្ថាប័ន |
|---|---|---|---|---|
| ការធ្វើបច្ចុប្បន្នភាពសេវាជូនប្រជាពលរដ្ឋ | មាន | N/A | N/A | គ.ជ.អ.ប |
| សេវារដ្ឋបាល | N/A | ខ្លះ | ខ្លះ | ការិយាល័យច្រកចេញចូលតែមួយ ក្រសួងមហាផ្ទៃ |
| 6. ភាពពេញចិត្តការផ្តល់សេវា | ខ្លះ | ខ្លះ | N/A | ការអង្កេតអភិបាលកិច្ច ដោយគ.ជ.អ.ប |
| 7. ភាពក្រីក្រ | មាន | មាន | មាន | ប្រព័ន្ធទិន្នន័យឃុំ សង្កាត់របស់ក្រសួងផែនការ |

លើសពីនេះ មានទិន្នន័យជាច្រើនដែលបានពីការវាយតម្លៃទៅលើសមិទ្ធផលរបស់ជ.អ.៣ មកដល់ពេលនេះ ដូចជា៖

- ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១១ និងឆ្នាំ២០១៣
- ការអង្កេតពាក់កណ្តាលអាណត្តិនៃការអនុវត្តជ.អ.៣ដំណាក់កាលទី១ ឆ្នាំ២០១២
- ការអង្កេតថ្នាក់ជាតិស្តីពីអភិបាលកិច្ច ឆ្នាំ២០១៣ និងឆ្នាំ២០១៦
- សវនកម្មយេនឌ័រ ឆ្នាំ២០១៣ និងឆ្នាំ២០១៦
- ការអង្កេតអភិបាលកិច្ចបែបគុណភាព ឆ្នាំ២០១៧
- ការអង្កេតពាក់កណ្តាលអាណត្តិនៃការអនុវត្តជ.អ.៣ដំណាក់កាលទី២ និងកម្មវិធីជាតិ ឆ្នាំ២០១៦
- ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៧
- ការសិក្សាស្រាវជ្រាវស្តីពីការអនុវត្តមូលនិធិឃុំ សង្កាត់ ឆ្នាំ២០០៨

## ៧.៤. របៀបវារៈ នៃការស្រាវជ្រាវ

ការស្រាវជ្រាវនឹងត្រូវបានប្រើប្រាស់ នៅក្នុងការវាយតម្លៃផលប៉ះពាល់ ដើម្បីស្វែងយល់ពីហេតុផល ផ្តត់គំនិត និងការលើកទឹកចិត្តអំពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ហើយការស្រាវជ្រាវផ្តល់ការយល់ដឹងអំពីបញ្ហាឬ ជួយបង្កើតគំនិតឬរៀបចំសកម្មភាពពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ ការស្រាវជ្រាវនេះ ក៏ជាមធ្យោបាយដើម្បីស្វែងយល់សារៈ និងជាឯកសារយោងសម្រាប់អ្នកស្រាវជ្រាវ និងអ្នករៀបចំគោលនយោបាយ ក្នុងការរៀបចំគោលនយោបាយ និងការសម្រេចចិត្តនានា។

របៀបវារៈនៃការស្រាវជ្រាវរបស់គ.ជ.អ.បអាចរកបាននៅក្នុង"យុទ្ធសាស្ត្រស្រាវជ្រាវរបស់គ.ជ.អ.ប"។ ជារួម របៀបវារៈនៃការស្រាវជ្រាវ ត្រូវបានរៀបចំឡើង ដើម្បីកំណត់វិសាលភាពនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលនឹងត្រូវសិក្សា និងវិធីសាស្ត្រដែលត្រូវប្រើប្រាស់ក្នុងការស្រាវជ្រាវ។ របៀបវារៈនៃការស្រាវជ្រាវគួរបង្កើតឲ្យមាននិងបង្ហាញពីការអនុវត្តជាក់ស្តែងនិងផ្អែកលើភស្តុតាង។

## ៧.៥. សកម្មភាពលើកកម្ពស់ការវាយតម្លៃ

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មានមានតួនាទីក្នុងការលើកកម្ពស់ការវាយតម្លៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលអនុវត្តដោយស្ថាប័នឬអ្នកពាក់ព័ន្ធនានា។ នៅក្នុងប្រទេសភាគច្រើន ការវាយតម្លៃភាគច្រើនត្រូវបានអនុវត្តយ៉ាងទូលំទូលាយដោយសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ។ ដើម្បីលើកកម្ពស់ការវាយតម្លៃឲ្យកាន់តែមានប្រសិទ្ធភាព ដែលអនុវត្តដោយស្ថាប័នឬអ្នកពាក់ព័ន្ធនានា គ.ជ.អ.ប ត្រូវរៀបចំផែនការដូចខាងក្រោម៖

១. រៀបចំសូចនាករស្តង់ដារនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងផ្សព្វផ្សាយដើម្បីឲ្យអ្នកស្រាវជ្រាវអាចយកទៅប្រើប្រាស់បាន

២. រៀបចំកិច្ចប្រជុំជាន់ខ្ពស់ជាមួយអ្នកនយោបាយ និងថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់កិច្ចសន្ទនាផ្នែកគោលនយោបាយ

៣.រៀបចំឬលើកកម្ពស់វេទិកាផ្សព្វផ្សាយ និងពិភាក្សាគោលនយោបាយរវាងអ្នកស្រាវជ្រាវ សាកលវិទ្យាល័យ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ ដៃគូពាក់ព័ន្ធនានា និងរាជរដ្ឋាភិបាល

៤. រៀបចំ ឬលើកកម្ពស់ព្រឹត្តិការណ៍ផ្សព្វផ្សាយនិងកិច្ចសន្ទនាអំពីគោលនយោបាយរវាងគ.ជ.អ.ប និងភាគីពាក់ព័ន្ធនានា។

# ជំពូកទី៨

# ក្របខណ្ឌលទ្ធផល

## ៨.១. សេចក្តីផ្តើម

ផ.អ.៣ត្រូវបានត្រួតពិនិត្យនិងវាយតម្លៃតាមរយៈក្របខណ្ឌលទ្ធផល ដែលរួមមាន សូចនាករ ចំណុចដៅ និង ប្រភពព័ត៌មានឬមធ្យោបាយផ្ទៀងផ្ទាត់។ សមិទ្ធផលសំខាន់ៗនៃផ.អ.៣ ត្រូវបានត្រួតពិនិត្យនិងវាយតម្លៃតាមវិធីសាស្ត្រ៣យ៉ាងដូចខាងក្រោម៖

១. សូចនាករផលប៉ះពាល់ ត្រូវបានប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃផ.អ.៣ដែលសម្រេចបាននៅកម្រិតគោលដៅ ដូចជាការពិនិត្យមើលជាសំខាន់ទៅលើភាពក្រីក្រ និងស្វ័យភាព

២. សូចនាករសមិទ្ធផលត្រូវបានប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃផ.អ.៣ដែលសម្រេចបាននៅកម្រិតគោលបំណង ដោយផ្តោតលើការផ្តល់សេវា អភិបាលកិច្ច សមត្ថភាព និងការផ្លាស់ប្តូរឥរិយាបទនៃមន្ត្រីរាជការ និងការអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្ត

៣. សូចនាករអនុវត្តសកម្មភាពនិងលទ្ធផលរំពឹងទុក ត្រូវបានប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃផ.អ.៣ដែលសម្រេចបាននៅកម្រិតលទ្ធផលរំពឹងទុកនិងសកម្មភាព តាមរយៈការអនុវត្ត ផ.ស.ថ ដោយផ្តោតលើ(ឧទាហរណ៍) លិខិតបទដ្ឋានគតិយុត្តស្តីពីការផ្ទេរមុខងារ ធនធានមនុស្ស និង ហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការអភិវឌ្ឍសមត្ថភាព និងការផ្សព្វផ្សាយព័ត៌មានស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

## ៨.២. សូចនាករផលប៉ះពាល់

លទ្ធផលនៃផ.អ.៣ដែលសម្រេចបាននៅកម្រិតគោលដៅ នឹងត្រូវវាស់វែងតាមរយៈប្រព័ន្ធទិន្នន័យថ្នាក់ឃុំសង្កាត់ (ដែលបានប្រមូលជារៀងរាល់ឆ្នាំដោយក្រសួងផែនការ) ប្រព័ន្ធទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ ការអង្កេតអភិបាលកិច្ច ការវាយតម្លៃនិងទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ។

## ៨.៣. សូចនាករសមិទ្ធផល

លទ្ធផលនៃផ.អ.៣ដែលសម្រេចបាននៅកម្រិតគោលបំណង នឹងត្រូវវាស់វែងតាមរយៈការអង្កេត ការវាយតម្លៃ ការសិក្សាស្រាវជ្រាវ ដូចជាការអង្កេតអភិបាលកិច្ច សវនកម្មយេនឌ័រ ការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនឹងត្រូវរៀបចំនិងសម្របសម្រួលដោយគ.ជ.អ.ប ព្រមទាំងទិន្នន័យដែលមានស្រាប់ពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។

## ៨.៤. សូចនាករអនុវត្តសកម្មភាព និងលទ្ធផលរំពឹងទុក

ផ.អ.៣ត្រូវបានអនុវត្តតាមរយៈផែនការប្រចាំឆ្នាំ(ផ.ស.ថ)។ ផ.ស.ថ រួមបញ្ចូលទាំងសូចនាករនិងចំណុចដៅនៃលទ្ធផលរំពឹងទុក និងសកម្មភាព។ សូចនាករទាំងនេះ នឹងត្រូវបានបង្កើតឡើងជារៀងរាល់ឆ្នាំ ដោយស្ថាប័នអនុវត្តផ.អ.៣ និងដោយមានការពិគ្រោះយោបល់ និងគាំទ្រដោយគ.ជ.អ.ប។ ក្របខណ្ឌលទ្ធផលផ.អ.៣បានកំណត់នូវសូចនាករអនុវត្តសកម្មភាពនិងលទ្ធផលរំពឹងទុក ដែលភាគច្រើនផ្តោតលើកម្រិតនៃការ អនុវត្តវិមជ្ឈការដោយរដ្ឋាភិបាល។

វិមជ្ឈការត្រូវបានយល់យ៉ាងទូលំទូលាយថា ជាដំណើរការ ដើម្បីពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងការលើកកម្ពស់ប្រសិទ្ធផលនៃការផ្តល់សេវាសាធារណៈ និងកិច្ចការរដ្ឋបាល។ កិច្ចដំណើរការនេះ ពាក់ព័ន្ធនឹង

ការបែងចែកមុខងារ និងការទទួលខុសត្រូវផ្នែកនយោបាយ សារពើពន្ធ និងកិច្ចការរដ្ឋបាល រវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

កម្រិតដែលរាជរដ្ឋាភិបាលអនុវត្តវិមជ្ឈការត្រូវបានកំណត់តាមរយៈច្បាប់និងបទបញ្ញា។ ក្របខណ្ឌលទ្ធផល ជ.អ.៣ត្រូវបានកំណត់វិសាលភាពនិងការវិវឌ្ឍនៃវិមជ្ឈការ តាមក្របខណ្ឌពេលវេលា និងការលើកកម្ពស់ស្វ័យភាពដែលបានផ្តល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូចនេះ ស្វ័យភាពនេះ នឹងត្រូវបានវាស់វែងតាមរយៈចង្កោមសូចនាករ ដូចជាវិមជ្ឈការខ្សែបណ្តោយ (តើរដ្ឋបាលមានប៉ុន្មានថ្នាក់) វិមជ្ឈការសិទ្ធិធ្វើសេចក្តីសម្រេច វិមជ្ឈការសិទ្ធិតែងតាំង វិមជ្ឈការការបោះឆ្នោត វិមជ្ឈការសារពើពន្ធ និងវិមជ្ឈការគ្រប់គ្រងបុគ្គលិក។

តារាងខាងក្រោមសង្ខេបសូចនាករអនុវត្តជ.អ.៣ទី៣។ សូចនាករទាំងនេះត្រូវបានប្រើក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាព។

# តារាងទី៩៖ ក្របខណ្ឌលទ្ធផល

| លទ្ធផលសង្ខេប | សូចនាករ | ចំណុចដៅ | | | | ឯកសារផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០១៨ | ២០១៩ | ២០២០ | |
| **គោលដៅ ៖ រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានស្វ័យភាព និងគណនេយ្យភាព** | | | | | | |
| | ១. សន្ទស្សន៍ភាពក្រីក្រគណនាតាមរយៈ CDB | ១៧,៥១ | | | | CDB ឆ្នាំ២០១៦របស់ក្រសួងផែនការ |
| **គោលបំណង៖ លើកកម្ពស់ការគ្រប់គ្រង អភិបាលកិច្ច ធនធាន និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| | ២. សន្ទស្សន៍ការពេញចិត្តក្នុងការផ្តល់សេវា | ៦៦ | ៧០,៤ | ៧៤,៨ | ៧៩,២ | សង្កេតអភិបាលកិច្ច |
| | ៣. សន្ទស្សន៍អភិបាលកិច្ច | | ៥២,៧ | ៥៦,០ | ៥៩,៣ | សង្កេតអភិបាលកិច្ច |
| | ៤. សន្ទស្សន៍សមត្ថភាពក្រុង ស្រុក ខណ្ឌ | ៥១,៥ | ៥៤,៩ | ៥៨,៤ | ៦១,៨ | ការវាយតម្លៃការអភិវឌ្ឍសមត្ថភាព |
| | ៥. ភាគរយនៃរដ្ឋបាលថ្នាក់ក្រោមជាតិទទួលពិន្ទុពេញចិត្តពីការធ្វើអធិការកិច្ច | | ២០ | ៣៥ | ៥០ | ដូចលទ្ធផលរំពឹងទុក ២.១.២. |
| | ៦. សន្ទស្សន៍សវនកម្មយេនឌ័រ | ៦៦,៦ | ៧១,០ | ៧៥,៥ | ៧៩,៩ | សវនកម្មយេនឌ័រ |
| **សមាសភាគទី១៖ ការគ្រប់គ្រងកំណែទម្រង់** | | | | | | |
| ១.១.១. កែសម្រួលរចនាសម្ព័ន្ធស្ថាប័ន | ៧. ចំនួនការវិភាគស្ថាប័ន កិច្ចប្រតិបត្តិការ និងការពិនិត្យមើលឡើងវិញបានអនុវត្ត | ០ | ១ | ២ | ៣ | របាយការណ៍ដែលបានរៀបចំ |
| | ៨. ចំនួនស្ថាប័នបានកែសម្រួលរចនាសម្ព័ន្ធស្របជាមួយវិមជ្ឈការ | ០ | ០ | ១ (មហាផ្ទៃ) | ៣ និងខេត្ត | លិខិតបទដ្ឋានដែលបានអនុម័ត |
| | ៩. លេខាធិការដ្ឋាន គ.ជ.អ.ប ក្លាយជាអង្គភាពថវិកា | | រៀបចំ | អនុវត្ត | អនុវត្ត | លិខិតបទដ្ឋានដែលបានអនុម័ត |
| ១.១.២. កម្មវិធីជាតិដំណាក់កាលបន្ទាប់ | ១០. កម្មវិធីជាតិបានរៀបចំ និងអនុម័ត | | | រៀបចំ | អនុម័ត | របាយការណ៍ប្រជុំ គ.ជ.អ.ប |
| | ១១. ការរៀបចំផែនការអនុវត្តដំណាក់កាលទី១ នៃកម្មវិធីជាតិដំណាក់កាលបន្ទាប់ | | | | អនុម័ត | របាយការណ៍ប្រជុំ គ.ជ.អ.ប |
| ១.១.៣. និរន្តរភាពផ្នែកហិរញ្ញវត្ថុកម្មវិធី | ១២. ចំនួនថវិការបស់រដ្ឋាភិបាលដែលផ្តល់សម្រាប់ចំណាយលើប្រតិបត្តិការនៃកិច្ចដំណើរការកំណែទម្រង់ (គិតជាលានដុល្លារ) | | ១,០ | ១,២៥ | ១,៥០ | ផ.ស.ថ ដែលបានអនុម័ត |
| | ១៣. ចំនួនថវិកាគាំទ្រដោយដៃគូអភិវឌ្ឍន៍សម្រាប់ជំនួយបច្ចេកទេស (គិតជាលានដុល្លារ) | | ៤ | ៣,៥ | ៣ | ផ.ស.ថ ដែលបានអនុម័ត |
| | ១៤. ចំនួនថវិកាគាំទ្រដោយដៃគូអភិវឌ្ឍន៍សម្រាប់ចំណាយផ្នែកប្រតិបត្តិការនៃ ផ.អ.៣ទី៣ (គិតជាលានដុល្លារ) | ២,៨ | ២ | ១,៨០ | ១,៦០ | ផ.ស.ថ ដែលបានអនុម័ត |
| | ១៥. ភាគរយចំណាយសមាគមក្រុមប្រឹក្សាទទួលបានពីកម្រៃសមាជិក និងពីរដ្ឋបាលថ្នាក់ក្រោមជាតិនានា | | ១០ | ២០ | ២០ | របាយការណ៍ហិរញ្ញវត្ថុរបស់សមាគម |
| ១.២.១. ការពិភាក្សាអំពីកំណែទម្រង់ | ១៦. ចំនួនកិច្ចប្រជុំប្រចាំឆ្នាំដែលបានរៀបចំ | ០ | ៣ | ៣ | ៣ | របាយការណ៍កិច្ចប្រជុំ |
| | ១៧. ចំនួនកិច្ចប្រជុំ គ.ជ.អ.ប ដែលបានរៀបចំ | ២ | ២ | ២ | ២ | កំណត់ហេតុកិច្ចប្រជុំ គ.ជ.អ.ប |
| ១.២.២. ការប្រាស្រ័យទាក់ទង | ១៨. សកម្មភាពផ្សព្វផ្សាយការផ្លាស់ប្តូរឥរិយាបទចំនួន១ កម្មវិធីទូរទស្សន៍ចំនួន១ សារព័ត៌មានចំនួន២ សេចក្តីប្រកាសព័ត៌មានចំនួន៣ និងសកម្មភាពនៃការអភិវឌ្ឍន៍សមត្ថភាពចំនួន៣ | | អនុវត្ត | អនុវត្ត | អនុវត្ត | របាយការណ៍ផ្សព្វផ្សាយនានា |
| | ១៩. ចំនួនលទ្ធផលរំពឹងទុករបស់ ផ.ស.ថ អនុវត្តការប្រាស្រ័យទាក់ទង | | ៥ | ៥ | ៥ | ប្រព័ន្ធទិន្នន័យ ផ.ស.ថ ឬរបាយការណ៍ប្រចាំឆ្នាំ |

| លទ្ធផលសង្ខេប | សូចនាករ | ចំណុចដៅ | | | | ឯកសារផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០១៨ | ២០១៩ | ២០២០ | |
| ១.២.៣. កម្មវិធីសាកល្បង | ២០. ចំនួនកម្មវិធីសាកល្បងស្ដីពីគោលនយោបាយដែលបានអនុវត្ត | ០ | ២ | ៣ | ៣ | របាយការណ៍ស្ដីពីការសាកល្បង |
| | ២១. ចំនួនការសាកល្បងឈានទៅដល់ការកែសម្រួលគោលនយោបាយ | ០ | ១ | ១ | ២ | របាយការណ៍ស្ដីពីការកែសម្រួល |
| ១.២.៤. តួនាទីសមាគមក្រុមប្រឹក្សា | ២២. ឯកសារគោលនយោបាយដែលបានធ្វើបទបង្ហាញ | គ្មាន | អនុវត្ត | អនុវត្ត | អនុវត្ត | កំណត់ហេតុវេទិកាគោលនយោបាយ |
| | ២៣. ការអនុវត្តយុទ្ធនាការ នៃការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានយ៉ាងតិចចំនួន១ក្នុងមួយឆ្នាំ | | អនុវត្ត | អនុវត្ត | អនុវត្ត | របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយ |
| ១.៣.១. ភាពជាដៃគូជាមួយសង្គមស៊ីវិល | ២៤. កម្មវិធីនៃភាពជាដៃគូបានកំណត់ និងផ្ដល់ហិរញ្ញប្បទាន | | រៀបចំ | ផ្ដល់ថវិកា | អនុវត្ត | កម្មវិធី និងកិច្ចព្រមព្រៀងនានា |
| | ២៥. ចំនួនលទ្ធផលរំពឹងទុកនៃ ផ.ស.ថ សហការជាមួយសង្គមស៊ីវិលឯកជន | ១ | ៥ | ៧ | ១០ | ឯកសារ ផ.ស.ថ និងផែនការគណនេយ្យភាពសង្គម |
| ១.៤.១. កិច្ចដំណើរការគ្រប់គ្រងគម្រោង | ២៦. ភាគរយនៃលទ្ធផលរំពឹងទុកបានរៀបចំជាគម្រោងបានអនុម័ត | | ៦០ | ១០០ | | ឯកសារគម្រោងនានា |
| | ២៧. ភាគរយនៃទិន្នន័យសូចនាករ ផ.អ.៣ទី៣ បានប្រមូល និងចងក្រង | ៧៩ | ៩០ | ៩០ | ៩០ | របាយការណ៍ប្រចាំឆ្នាំនៃ ផ.ស.ថ |
| | ២៨. ភាគរយនៃចំណុចដៅ ផ.អ.៣ទី៣ ដែលបានសម្រេច | ២៥ | ៥០ | ៦០ | ៧០ | ផ.ស.ថ និងរបាយការណ៍ប្រចាំឆ្នាំ |
| | ២៩. ភាគរយនៃចំណុចដៅនៃ ផ.ស.ថ ដែលបានសម្រេច | | ៨០ | ៨០ | ៨០ | ផ.ស.ថ និងរបាយការណ៍ប្រចាំឆ្នាំ |
| ១.៤.២. សុខដុមនីយកម្មគម្រោង | ៣០. ការសិក្សាឯករាជ្យបានអនុម័តដោយក្រុមបច្ចេកទេសSNDD | | អនុម័ត | | | កំណត់ហេតុក្រុមបច្ចេកទេសSNDD |
| ១.៤.៣. ការគ្រប់គ្រងកម្មវិធីជាប្រចាំ | ៣១. ចំនួនហានិភ័យកម្រិតខ្ពស់ និងមធ្យមកំណត់ក្នុងរបាយការណ៍សវនកម្ម | | ១១ | ៧ | ៥ | របាយការណ៍សវនកម្មឯករាជ្យ |
| **សមាសភាគទី ២៖ អភិបាលកិច្ចល្អ** | | | | | | |
| ២.១.១. គណនេយ្យភាពសង្គម | ៣២. ផែនការយុទ្ធសាស្ត្រស្ដីពីគណនេយ្យភាពសង្គម ដំណាក់កាលបន្ទាប់បានអនុម័ត | | អនុម័ត | | | ឯកសារផែនការយុទ្ធសាស្ត្រ |
| | ៣៣. លិខិតបទដ្ឋានស្ដីពីការប្រើប្រាស់ព័ត៌មានរបស់ប្រជាពលរដ្ឋបានអនុម័ត | គ្មាន | | | អនុម័ត | លិខិតបទដ្ឋានដែលបានអនុម័ត |
| | ៣៤. ភាគរយនៃ I4C អំពីការផ្ដល់សេវាបានប្រមូល និងបញ្ចូលក្នុងកុំព្យូទ័រ | ៨៧ | ៩០ | ៩៥ | ៩៥ | ប្រព័ន្ធទិន្នន័យគណនេយ្យភាពសង្គម |
| ២.១.២. ការដោះស្រាយបណ្ដឹង | ៣៥. យន្តការបណ្ដឹងបានរៀបចំ ប្រើប្រាស់ និងផ្សព្វផ្សាយ | | រៀបចំ | អនុវត្ត | វាយតម្លៃ | របាយការណ៍ការិយាល័យច្រកចេញចូលតែមួយ |
| | ៣៦. ចំនួនមតិយោបល់និងបណ្ដឹងបានសម្រុះសម្រួលដោះស្រាយ | ៣៧៨ | ៥០០ | ១.៥០០ | ២.០០០ | របាយការណ៍ MOI និងទិន្នន័យបណ្ដឹង |
| | ៣៧. ភាគរយបណ្ដឹងទទួលបានតាមរយៈទូរស័ព្ទ ឬវែបសាយ | | | ២០ | ៣០ | របាយការណ៍ MEID |
| | ៣៨. ភាគរយបណ្ដឹងដោះស្រាយក្នុងពេលវេលាកំណត់ | គ្មាន | ៥០ | ៦០ | ៧០ | ប្រព័ន្ធត្រួតពិនិត្យបណ្ដឹង ឬរបាយការណ៍ការិយាល័យច្រកចេញចូលតែមួយ |
| ២.២.១. ការពង្រឹងតួនាទីក្រុមប្រឹក្សា | ៣៩. នីតិវិធីទំនាក់ទំនងរវាងក្រុមប្រឹក្សា-ប្រជាពលរដ្ឋ និងទំនាក់ទំនងរវាង DM និង CS | | ការពិនិត្យ | ការកែសម្រួល | អនុវត្ត | សេចក្ដីណែនាំដែលបានអនុម័ត |
| ២.៣.១. អធិការកិច្ច | ៤០. ចំនួនសរុប SNAs បានធ្វើអធិការកិច្ចដោយក្រសួងមហាផ្ទៃ | ០ | | ១០ | ២០ | របាយការណ៍អធិការកិច្ចរបស់ MOI |
| | ៤១. ភាគរយ SNAs បានធ្វើអធិការកិច្ចដោយ MOI ទទួលបានពិន្ទុពេញចិត្ត | | | ២០ | ៣០ | របាយការណ៍អធិការកិច្ចរបស់ MOI |
| | ៤២. ចំនួនសរុបនៃក្រសួង ស្ថាប័ន(លើកលែងមហាផ្ទៃ) បានធ្វើអធិការកិច្ច | ០ | ០ | ២ | ៤ | របាយការណ៍របស់ក្រសួងពាក់ព័ន្ធ |
| ២.៣.២. ការវាយតម្លៃ SNAs ប្រចាំឆ្នាំ | ៤៣. ក្របខ័ណ្ឌវាយតម្លៃលទ្ធផលនៃការបំពេញការងាររបស់ SNAs | | អនុម័ត | អនុវត្ត | អនុវត្ត | របាយការណ៍អំពីការប្រើប្រាស់មូលនិធិ |
| | ៤៤. ចំនួនក្រុង ស្រុកបានរៀបចំផែនការកែលម្អការងារ | ០ | | ៣០ | ៨០ | របាយការណ៍វាយតម្លៃរបស់ក្រសួងពាក់ព័ន្ធ |
| | ៤៥. ប្រព័ន្ធផ្ដល់មូលនិធិលើកទឹកចិត្តដល់ SNAs | | | បានរៀបចំ | សាកល្បង | របាយការណ៍អំពីការប្រើប្រាស់មូលនិធិ |

| លទ្ធផលសង្ខេប | សូចនាករ | ចំណុចដៅ | | | | ឯកសារផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០១៨ | ២០១៩ | ២០២០ | |
| ២.៤.១. ការពិនិត្យមើលប្រព័ន្ធគ្រប់គ្រង | ៤៦. ការពិនិត្យមើលឡើងវិញលើប្រព័ន្ធគ្រប់គ្រងរបស់ SNAs | | សាកល្បង | អនុវត្ត | អនុវត្ត | របាយការណ៍របស់ MOI |
| ២.៤.២. ប្រព័ន្ធM&E និងMIS | ៤៧. ភាគរយនៃរដ្ឋបាលក្រុង ស្រុកទទួលបាន និងប្រើប្រាស់ប្រព័ន្ធ MIS | | ២០ | ៥០ | ៨០ | ទិន្នន័យ MIS របស់ក្រុង ស្រុក |
| ២.៤.៣. ប្រព័ន្ធកសាងផែនការ | ៤៨. ភាគរយក្រុង ស្រុកមានលទ្ធផលពីរងទុកយ៉ាងតិចចំនួន៥ក្នុងផែនការ.... | ០ | ២០ | ៥០ | ៩០ | ទិន្នន័យ SPD |
| ២.៤.៤. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ | ៤៩. ប្រព័ន្ធហិរញ្ញវត្ថុបានកែសម្រួល និងដាក់ឲ្យប្រើប្រាស់ | | វិភាគ | សាកល្បង | អនុវត្ត | លិខិតបទដ្ឋាននានាស្តីពីការផ្លាស់ប្តូរប្រព័ន្ធ |
| ២.៥.១. ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម តាមរយៈការដឹកនាំ | ៥០. ប្រព័ន្ធទិន្នន័យមូលដ្ឋានបុគ្គលិកបានរៀបចំ | | វិភាគ | សាកល្បង | អនុវត្ត | ទិន្នន័យក្នុងប្រព័ន្ធដែលបានធ្វើបច្ចុប្បន្នភាព |
| | ៥១. យុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង | | រៀបចំ | អនុវត្ត | អនុវត្ត | ផែនការយុទ្ធសាស្ត្រដែលបានអនុម័ត |
| | ៥២. ភាគរយអភិបាល អភិបាលរងបានរៀនវគ្គកាតព្វកិច្ចស្តីពីយេនឌ័រ | ០ | ៩៥ | ៩៥ | ៩៥ | របាយការណ៍វគ្គបណ្តុះបណ្តាល |
| | ៥៣. ភាគរយស្ត្រីថ្នាក់រាជធានី ខេត្តកាន់មុខតំណែងគ្រប់គ្រង | ១២,១ | ២០ | ២២ | ២៥ | ប្រព័ន្ធទិន្នន័យបុគ្គលិក |
| | ៥៤. ភាគរយស្ត្រីក្រុង ស្រុក ខណ្ឌកាន់មុខតំណែងគ្រប់គ្រង | ២១,៥ | ២៥ | ២៧ | ៣០ | ប្រព័ន្ធទិន្នន័យបុគ្គលិក |
| ២.៥.២. បរិយាប័ន្ននិងសមធម៌សង្គម | ៥៥. ចំនួនកម្មវិធីដែលបានអនុវត្តក្នុងការលើកកម្ពស់យុវជន ជនពិការ ជនជាតិដើម... | | រៀបចំ | ១ | ២ | ផែនការសកម្មភាព និងថវិកា |
| | ៥៦. ភាគរយនៃការកើនឡើងពិន្ទុនៃការបញ្ជ្រាបយេនឌ័រក្នុងសវនកម្មយេនឌ័រ | | | | ១៥% | របាយការណ៍សវនកម្មយេនឌ័រ |
| ២.៥.៣. សេវាសុវត្ថិភាពសង្គម | ៥៧. SNA ផ្តល់មូលនិធិគាំទ្រសុវត្ថិភាពសង្គម ( គិតជាលានដុល្លារ ) | | ១ | ២ | ៣ | ទិន្នន័យ SPD |
| ២.៥.៤. CD បរិយាប័ន្ននិងសមធម៌សង្គម | ៥៨. ក្រសួង ស្ថាប័ន និង SNAs ផ្តល់ថវិកាគាំទ្រគណៈកម្មាធិការ/ក្រុមការងារយេនឌ័រ | ៩.៧ | អនុវត្ត | អនុវត្ត | អនុវត្ត | ផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នអនុវត្ត |
| **សមាសភាគទី៣ ៖ ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស** | | | | | | |
| ៣.១.១. ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស | ៥៩. ភាគរយ SNAs ជ្រើសរើសបុគ្គលិកតាមបែបបទ និងនីតិវិធីគ្រប់គ្រងបុគ្គលិក | ០ | | ៧០ | ១០០ | របាយការណ៍បុគ្គលិករបស់ SNAs |
| | ៦០. ភាគរយនាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌវាយតម្លៃដោយ BoG | ០ | | ២៥ | ៧៥ | របាយការណ៍នាយកដ្ឋានបណ្តុះបណ្តាល |
| ៣.២.១. អភិក្រមនៃការអភិវឌ្ឍសមត្ថភាព | ៦១. សេចក្តីណែនាំស្តីពីការអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាព... | ០ | រៀបចំ | អនុវត្ត | អនុវត្ត | របាយការណ៍នាយកដ្ឋានបណ្តុះបណ្តាល |
| | ៦២. ចំនួន SNAs ទទួលថវិកាអភិវឌ្ឍន៍សមត្ថភាព | ០ | រៀបចំ ប្រព័ន្ធ | ២០ | ៤០ | របាយការណ៍នាយកដ្ឋានបណ្តុះបណ្តាល |
| ៣.២.២. ការអភិវឌ្ឍសមត្ថភាព | ៦៣. ភាគរយឃុំ សង្កាត់បានបញ្ចប់សកម្មភាព៖ បណ្តុះបណ្តាល១លើក... | | ៥០ | ៧០ | ៩០ | របាយការណ៍នាយកដ្ឋានបណ្តុះបណ្តាល |
| | ៦៤. ភាគរយក្រុង ស្រុកបានបញ្ចប់សកម្មភាព៖ បណ្តុះបណ្តាល១លើក... | | ៥០ | ៧០ | ៩០ | របាយការណ៍នាយកដ្ឋានបណ្តុះបណ្តាល |
| | ៦៥. ភាគរយរាជធានី ខេត្តបានបញ្ចប់សកម្មភាព៖ បណ្តុះបណ្តាល១លើក... | | ៥០ | ៧០ | ៩០ | របាយការណ៍នាយកដ្ឋានបណ្តុះបណ្តាល |
| ៣.២.៣. រចនាសម្ព័ន្ធអភិវឌ្ឍសមត្ថភាព | ៦៦. រចនាសម្ព័ន្ធស្ថាប័នអភិវឌ្ឍសមត្ថភាពបានកែសម្រួល និងពង្រឹង | | ទីចាត់ការ CD បាន បង្កើត | អនុវត្ត អនុសាសន៍ CD | ដំណើរការ សាលាជាតិ | លិខិតបទដ្ឋានដែលបានអនុម័ត |
| **សមាសភាគទី៤ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** | | | | | | |
| ៤.១.១. លិខិតបទដ្ឋានអំពីអាណត្តិទូទៅ | ៦៧. ភាគរយអនុសាសន៍ត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាប្រឈមនានា | ០ | ការ ពិនិត្យឡើងវិញ | ២៥ | ៧៥ | ផែនការសកម្មភាពលើកកម្ពស់ការអនុវត្តអាណត្តិទូទៅ |

| លទ្ធផលសង្ខេប | សូចនាករ | ចំណុចដៅ | | | | ឯកសារផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០១៨ | ២០១៩ | ២០២០ | |
| | ៦៨. ភាគរយនៃកំណើនចំណាយរបស់ឃុំ សង្កាត់ ក្រុង ស្រុក លើសេវាសង្គម | | ២៥ | ១០០ | ២០០ | ប្រព័ន្ធទិន្នន័យ SPD |
| ៤.១.២. បទពិសោធន៍អំពីអាណត្តិទូទៅ | ៦៩. ចំនួនសរុបនៃបទពិសោធន៍ល្អៗរបស់ SNA បានចងក្រងជាឯកសារ | ០ | ១៥ | ៣០ | ៤៥ | សេចក្តីណែនាំដែលបានអនុម័ត |
| | ៧០. សេចក្តីណែនាំស្តីពីបទពិសោធន៍ល្អៗត្រូវបានដាក់ឲ្យអនុវត្ត | | អនុវត្ត | អនុវត្ត | អនុវត្ត | របាយការណ៍របស់ MOI |
| | ៧១. ចំនួនសរុបនៃ SNA បានអនុវត្តបទពិសោធន៍ល្អៗ | | | ១០ | ៣០ | កម្មវិធីសិក្សា ឬប្រព័ន្ធ SPD |
| ៤.១.៣. កញ្ចប់មូលនិធិអាណត្តិទូទៅ | ៧២. ចំនួនសរុបនៃគម្រោងសហគមន៍ គាំទ្រដោយ LCPF | | ០ | ៣០ | ៩០ | របាយការណ៍ស្តីពីការអនុវត្ត LCPF |
| | ៧៣. ចំនួនសរុបនៃគម្រោង សកម្មភាព SNA គាំទ្រដោយ SIF | | ០ | ១០ | ២០ | របាយការណ៍ស្តីពីការអនុវត្ត SIF |
| | ៧៤. ចំនួនសរុបនៃគម្រោង សកម្មភាពរួមគ្នារវាង SNA-CSOs គាំទ្រដោយ CSPF | | ០ | ៥ | ១០ | របាយការណ៍ស្តីពីការអនុវត្ត CSPFឬប្រព័ន្ធ SPD |
| ៤.១.៤. ការអនុវត្តអាណត្តិទូទៅ | ៧៥. ចំនួនសរុបនៃឃុំ សង្កាត់ទទួលបានការគាំទ្រអនុវត្តអាណត្តិទូទៅ | | ២៥ | ១៥០ | ៤០០ | របាយការណ៍ CD របស់មណ្ឌល |
| | ៧៦. ចំនួនសរុបនៃក្រុង ស្រុកទទួលបានការគាំទ្រអនុវត្តអាណត្តិទូទៅ | | ២៥ | ១៥០ | ១៨៥ | របាយការណ៍ CD របស់មណ្ឌល |
| ៤.១.៥. គម្រោងប្រែប្រួលអាកាសធាតុ... | ៧៧. ភាគរយគម្រោងប្រែប្រួលអាកាសធាតុនិងសេវាសង្គម ផ្ទេរថវិកាតាមប្រព័ន្ធរតនាគារ | | ២០ | ៤០ | ៦០ | ការវិភាជ និងការផ្ទេរមូលនិធិទៅឲ្យ SNAs |
| ៤.២.១. លិខិតបទដ្ឋានផ្ទេរមុខងារ | ៧៨. ចំនួនសរុបនៃការសិក្សាអំពីការចំណាយសម្រាប់ការអនុវត្តមុខងារត្រូវផ្ទេរ | ០ | ៤ | ១១ | ១១ | របាយការណ៍របស់ក្រសួងពាក់ព័ន្ធ |
| | ៧៩. ចំនួនសរុបនៃក្រសួង ស្ថាប័នបានរៀបចំបញ្ចប់លិខិតបទដ្ឋានប្រតិភូកម្មមុខងារ | ២ | ៥ | ១០ | ១៤ | លិខិតបទដ្ឋានដែលបានអនុម័ត |
| ៤.២.២. ផែនការផ្ទេរមុខងារ | ៨០. ចំនួនសរុបនៃផែនការផ្ទេរមុខងារដែលបានអនុវត្ត | ០ | ៦ | ១២ | ១៤ | ផែនការសកម្មភាពផ្ទេរមុខងារ |
| ៤.២.៣. ការអនុវត្តការផ្ទេរមុខងារ | ៨១. ចំនួនខេត្តដែលមានក្រុង ស្រុកអនុវត្តមុខងារអប់រំដែលបានផ្ទេរ | ០ | ០ | ១ | ២ | ផែនការសកម្មភាពផ្ទេរមុខងារ |
| | ៨២. ចំនួនសរុបនៃស្រុកអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | | ៥ | ៥០ | ១០០ | ផែនការសកម្មភាពផ្ទេរមុខងារ |
| | ៨៣. ចំនួនក្រុងអនុវត្តមុខងារទីប្រជុំជនយ៉ាងតិចចំនួន២ | | | ១០ | ២៦ | ផែនការសកម្មភាពផ្ទេរមុខងារ |
| | ៨៤. ចំនួនធនធានហិរញ្ញវត្ថុមានភ្ជាប់ល័ក្ខខ័ណ្ឌផ្ទេរឲ្យSNAsអនុវត្តមុខងារ (លានដុល្លារ) | | ២ | ៤ | ៨ | ទិន្នន័យថវិការបស់ MEF |
| ៤.២.៤. យន្តការច្រកចេញចូលតែមួយ | ៨៥. ចំនួនប្រជាពលរដ្ឋទទួលសេវាតាមរយៈយន្តការច្រកចេញចូលតែមួយ | ៦៦៧.៨១៦ | ៧៥០.០០០ | ៩០០.០០០ | ១.៣០០.០០០ | របាយការណ៍របស់ MOI |
| | ៨៦. ចំនួនសរុបនៃប្រភេទសេវារដ្ឋបាលបានផ្តល់ | ២៣២ | ២៤០ | ២៤៥ | ២៥៥ | របាយការណ៍របស់ MOI |
| | ៨៧. ចំនួនសរុបSNAs ផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ | ៥២ | ១០០ | ១៥០ | ១៧៥ | របាយការណ៍របស់ MOI ឬការិយាល័យច្រកចេញចូលតែមួយ |
| ៤.៣.១. ស្តង់ដាររបស់ក្រសួង | ៨៨. ចំនួនសរុបនៃក្រសួង ស្ថាប័នបានកែសម្រួលស្តង់ដា និងលិខិតបទដ្ឋាន | ០ | ១ | ៣ | ៥ | លិខិតបទដ្ឋាន យុទ្ធសាស្ត្រក្រសួងពាក់ព័ន្ធ |
| ៤.៤.១. កែសម្រួលរចនាសម្ព័ន្ធខេត្ត | ៨៩. រចនាសម្ព័ន្ធ តួនាទី ការទទួលខុសត្រូវ បុគ្គល ថវិកា ត្រូវបានកែសម្រួល | ០ | ការសិក្សា | ការកែសម្រួល | | របាយការណ៍នានារបស់ MOI |
| ៤.២.២. ក្រុង ស្រុកគាំទ្រឃុំ សង្កាត់ | ៩០. លិខិតបទដ្ឋានណែនាំអំពីបែបផែនគាំទ្ររដ្ឋបាលដល់ឃុំ សង្កាត់បានកែលម្អ | ០ | ការពិនិត្យ | អនុវត្ត | | របាយការណ៍នានារបស់ MOI |
| **សមាសភាគទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ** | | | | | | |
| ៥.១.១. មូលនិធិក្រុង ស្រុកនិងឃុំ សង្កាត់ | ៩១. ភាគរយផ្នែកអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុកធៀបនឹងចំណូលចរន្តនៃថវិកាជាតិ | ០,៣៥ | ០,៣៧ | ០,៥០ | ០,៥០ | ច្បាប់ថវិកាប្រចាំឆ្នាំ |
| | ៩២. ប្រព័ន្ធបែងចែកមូលនិធិដោយសមធម៌ត្រូវបានរៀបចំ | | អនុម័ត | អនុវត្ត | អនុវត្ត | លិខិតបទដ្ឋាន និងការវិភាជ |
| | ៩៣. លិខិតបទដ្ឋានស្តីពីការលើកទឹកចិត្តផ្អែកលើលទ្ធផលនៃការបំពេញការងារ | | អនុម័ត | សាកល្បង | អនុវត្ត | លិខិតបទដ្ឋានបានអនុម័ត |

| លទ្ធផលសង្ខេប | សូចនាករ | ចំណុចដៅ | | | | ឯកសារផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|
| | | ដើមគ្រា | ២០១៨ | ២០១៩ | ២០២០ | |
| ៥.១.២. កែសម្រួលចំណូលចែករំលែក | ៩៤. %ចំណូលសារពើពន្ធនៃគុណប្រយោជន៍ថវិកាខេត្តចែករំលែកទៅឲ្យក្រុង ស្រុក | | ៣% | ៣% | ៣% | ច្បាប់ថវិកាប្រចាំឆ្នាំ |
| | ៩៥. %ចំណូលសារពើពន្ធនៃគុណប្រយោជន៍ថវិកាខេត្តចែករំលែកទៅឲ្យឃុំ សង្កាត់ | | ១% | ១% | ១% | ច្បាប់ថវិកាប្រចាំឆ្នាំ |
| ៥.១.៣. ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ | ៩៦. ចំនួនក្រុង ស្រុកទទួលបានធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ | ០ | ០ | ១៥ | ៤០ | ច្បាប់ថវិកាប្រចាំឆ្នាំឬរបាយការណ៍ MEF |
| ៥.១.៤. មូលនិធិវិនិយោគ SNIF | ៩៧. តម្លៃសរុបនៃគម្រោងដែលបានអនុវត្ត (គិតជាលានដុល្លារ) | ០ | ៥,៨២ | ៦,៧៥ | ៨,២៤ | របាយការណ៍ SNIF |